ធនាគារ អេស ប៊ី អាយ លី ហួរ
SBI LY HOUR Bank




# របាយការណ៍ ប្រចាំឆ្នាំ ២០២១



# មាតិកា

## ០១ | អំពីធនាគារ


១.១ ទិន្នន័យសំខាន់ៗ

១.២ ប្រវត្តិធនាគារ

១.៣ បេសកកម្ម ទស្សនៈវិស័យ និងតម្លៃរួម

១.៤ ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

១.៥ ចំណាប់អារម្មណ៍របស់អគ្គនាយកស្តីទី

១.៦ ក្រុមប្រឹក្សាភិបាល

១.៧ គណៈគ្រប់គ្រងជាន់ខ្ពស់

១.៨ រចនាសម្ព័ន្ធគណៈគ្រប់គ្រង

១.៩ ការគ្រប់គ្រងហានិភ័យ

១.១០ ធនធានមនុស្ស

១.១១ ផលិតផល និងសេវាកម្ម

១.១២ ធនាគារឌីជីថល


## ០២ | របាយការណ៍ហិរញ្ញវត្ថុ


២.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

២.២ របាយការណ៍របស់សវនករឯករាជ្យ

២.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

២.៤ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

២.៥ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

២.៦ របាយការណ៍លំហូរទឹកប្រាក់


## ០៣ | បណ្តាញសាខាទំនាក់ទំនង


៣.១ ការិយាល័យស្នាក់ការ

៣.២ បណ្តាញសាខា

# SBI Holdings, Inc.



# ០១ | អំពីធនាគារ


១.១ ទិន្នន័យសំខាន់ៗ ០៣

១.២ ប្រវត្តិធនាគារ ០៥

១.៣ បេសកកម្ម ទស្សនវិស័យ និងតម្លៃរួម ០៦

១.៤ ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ០៧

១.៥ ចំណាប់អារម្មណ៍របស់អគ្គនាយក ០៩

១.៦ ក្រុមប្រឹក្សាភិបាល ១១

១.៧ គណៈគ្រប់គ្រងជាន់ខ្ពស់ ១៥

១.៨ រចនាសម្ព័ន្ធគណៈគ្រប់គ្រង ២៩

១.៩ ការគ្រប់គ្រងហានិភ័យ ៣១

១.១០ ធនធានមនុស្ស ៣៣

១.១១ ផលិតផល និងសេវាកម្ម ៣៥

១.១២. ធនាគារឌីជីថល ៤១

# ១.១ ទិន្នន័យសំខាន់ៗ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ២០២០ | ២០២១ |
|---|---|---|
| ទ្រព្យសកម្មសរុប (លានដុល្លារអាមេរិក) | ២៤៣ | ៦២៣ |
| ផលប័ត្រប្រាក់កម្ចី (លានដុល្លារអាមេរិក) | ១៩៥ | ៤៩៩ |
| ប្រាក់បញ្ញើសរុប (លានដុល្លារអាមេរិក) | ១២០ | ៤៤៤ |
| មូលធនសរុប (លានដុល្លារអាមេរិក) | ៧៦ | ៨២ |

## លទ្ធផលហិរញ្ញវត្ថុ

| | ២០២០ | ២០២១ |
|---|---|---|
| ចំណូលការប្រាក់សុទ្ធ (គិតជាពាន់ដុល្លារអាមេរិក) | ១២,១៥១ | ៣១,៣៨៤ |
| ចំណូលផ្សេងៗសុទ្ធ (គិតជាពាន់ដុល្លារអាមេរិក) | ៦៥៥ | ៥០៩ |
| ប្រាក់(ខាត)/ចំណេញសុទ្ធ (គិតជាពាន់ដុល្លារអាមេរិក) | ៧៨២ | ៦,១២១ |

## សូចនាករសំខាន់ៗ

| | ២០២០ | ២០២១ |
|---|---|---|
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្មសរុប (គិតជាភាគរយ) | -០.៣២% | ០.៩៨% |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន (គិតជាភាគរយ) | -១.០៣% | ៧.៤៦% |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន (គិតជាភាគរយ) | ៦.១៧% | ១០.១៣% |
| អនុបាតទិន្នផលដុលសរុប (គិតជាភាគរយ) | ៧.៦៣% | ៧.៨៩% |



# បណ្ដាញសាខាទាំង

# ៤៥

# ក្នុង ២៥ ខេត្ត រាជធានី

# ១.២ ប្រវត្តិធនាគារ

**ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ហៅកាត់ថា "ធនាគារ" គឺជាសម្ព័ន្ធអាជីវកម្មរវាង អ្នកឧកញ៉ា លី ហួរ និង ក្រុមហ៊ុន** SBI Holdings, Inc.**។ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាក្រុមហ៊ុនចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។**

ទស្សនៈវិស័យរបស់ធនាគារគឺផ្តល់ជូននូវសេវាកម្ម និងផលិតផលធនាគារពាណិជ្ជដល់ រូបវន្តបុគ្គល សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុន និងសាជីវកម្មជាទូទៅដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀតដែលអនុវត្តដោយធនាគារពាណិជ្ជកម្មអន្តរជាតិ។ គោលបំណងចម្បងរបស់ធនាគារគឺដើម្បីជួយដល់អាជីវកម្ម និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការរីកចម្រើនអាជីវកម្មដោយផ្តល់ជូននូវសេវាកម្មធនាគារដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ បច្ចេកវិទ្យាជឿនលឿន ការផ្តល់ហិរញ្ញប្បទានដែលមានតម្លៃសមរម្យ និងនាំមកនូវបច្ចេកវិទ្យាហិរញ្ញវត្ថុចុងក្រោយដើម្បីផ្តល់បទពិសោធន៍របស់អ្នកប្រើប្រាស់កាន់តែងាយស្រួល និងទាក់ទាញ។



# ១.៣ បេសកកម្ម ទស្សនៈវិស័យ និងតម្លៃរួម

## បេសកកម្ម

ធនាគារឈានមុខគេប្រកបដោយការជឿជាក់ ជាមួយនវានុត្តន៍ហិរញ្ញវត្ថុតាមរយៈការបន្តអភិវឌ្ឍខ្លួនប្រកបដោយទំនួលខុសត្រូវផ្នែកសង្គម។

## ទស្សនៈវិស័យ

ជម្រុញនិងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុតាមរយៈប្រព័ន្ធធនាគារឌីជីថលដ៏ទំនើបប្រតិបត្តិការធនាគារដែលមានទំនុកចិត្ត និងបណ្តាញភ្នាក់ងារក្នុងព្រះរាជាណាចក្រកម្ពុជា។

## តម្លៃរួម

សុចរិតភាព៖ ការប្រព្រឹត្តត្រឹមត្រូវ និងស្មោះត្រង់។
ភាពជាអ្នកដឹកនាំ៖ ទាំងអស់គ្នាជាអ្នកដឹកនាំ។
សហប្រតិបត្តិការ៖ រួមគ្នាសម្រេចគោលដៅ។
ការទទួលខុសត្រូវ៖ ខ្ញុំធ្វើគឺខ្ញុំទទួលខុសត្រូវ។
អតិថិជនជាចម្បង៖ យើងខ្ញុំប្តេជ្ញាផ្តល់ជូនសេវាកម្មល្អឥតខ្ចោះ។





# ១.៤ ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

**ឆ្នាំ២០២១ គឺជាឆ្នាំទី២ និងជាឆ្នាំដែលមមាញឹក និងអភិវឌ្ឍដ៏ខ្លាំងបំផុត សម្រាប់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គិតចាប់តាំងពីការក្លាយខ្លួនជាធនាគារពាណិជ្ជ។**

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានធ្លាក់ចុះអត្រាកំណើនផលិតផលក្នុងស្រុក (GDP) ស្ថិតក្នុងកម្រិតទាប បន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ នៅតែបន្តរីករាលដាលខ្លាំងចូលដល់ក្នុងសហគមន៍ ដែលជាហេតុធ្វើឱ្យរាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចាំបាច់ទប់ស្កាត់ការរីករាលដាល តាមរយៈដាក់ប្រទេសក្នុងស្ថានភាពបិទខ្ទប់ និងរឹតបន្តឹងក្នុងការធ្វើចរាចរណ៍ ការធ្វើអាជីវកម្មមួយចំនួន និងជំរុញឱ្យមានការចាក់វ៉ាក់សាំងគ្រប់ប្រជាជនទាំងអស់ក្នុងប្រទេសកម្ពុជា។ លើសពីនេះផងដែរធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលការណ៍សំខាន់ៗមួយចំនួនរួមមានការរៀបចំឥណទានឡើងវិញជូនដល់ប្រជាពលរដ្ឋក្នុងគោលបំណងដើម្បីជួយបន្ធូរបន្ថយស្ថានភាពអាជីវកម្មរបស់អតិថិជនដែលកំពុងប៉ះពាល់ជាការសបញ្ជាក់ឱ្យឃើញថាយន្តការពិសេសក្រោមការដាក់ចេញរបស់រាជរដ្ឋាភិបាល និងតួនាទីរបស់គ្រឹះស្ថាន ធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានាបានដើរតួយ៉ាងសំខាន់ ក្នុងការស្តារប្រទេសត្រលប់មករកភាពវិជ្ជមានឡើងវិញ។

បើយើងក្រលេកមើលទិដ្ឋភាពទាំងមូលរបស់ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក វិញ ក្នុងឆ្នាំទី២ បន្ទាប់ពីបានក្លាយខ្លួនទៅជា ធនាគារពាណិជ្ជ ធនាគារបាននឹងកំពុងបន្តអភិវឌ្ឍ ផលិតផល សេវាកម្ម ប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ ពង្រីកតំបន់ប្រតិបត្តិការសាខាគ្របដណ្តប់ទូទាំងប្រទេស ក្នុងគោលបំណងដើម្បីចាប់យកចំណែកទីផ្សារស្របទៅតាមទិសដៅនិងផែនការអាជីវកម្មដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជនទោះបីជាបានទទួលរងនូវផលប៉ះពាល់ពីជំងឺកូវីដ-១៩ ចំពោះអតិថិជន បុគ្គលិកក៏ដោយប្រតិបត្តិការរបស់ធនាគារ អាចបន្តដំណើរការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ស្របតាមយុទ្ធសាស្ត្រ របស់គណៈគ្រប់គ្រងធនាគារ ការប្រើប្រាស់នូវប្រព័ន្ធអេកូអាជីវកម្មរបស់បណ្តាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ភាគទុនិក និងការខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់គណៈគ្រប់គ្រងបុគ្គលិកគ្រប់ជាន់ថ្នាក់ ជាលទ្ធផល ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ត្រូវបានមហាជនទទួលស្គាល់យ៉ាងខ្លាំងក្នុងវិស័យហិរញ្ញវត្ថុទាំងមូលក្នុងប្រទេសកម្ពុជា។ លើសពីនេះផងដែរផែនការប្រាក់ចំណេញរបស់ធនាគារផលប័ត្រឥណទាន ប្រាក់បញ្ញើរបស់ធនាគារ ត្រូវបានកើនឡើងលើសពី ១០០% បើធៀបទៅនឹងឆ្នាំ២០២០។

តាំងនាមឱ្យភាគទុនិកប្រធានក្រុមប្រឹក្សាភិបាល និងតំណាងឱ្យធនាគារទាំងមូល យើងខ្ញុំសូមធ្វើការថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូនដល់អាជ្ញាធរពាក់ព័ន្ធធនាគារដៃគូសវនករឯករាជ្យអតិថិជនជាទីគោរពទាំងអស់ដែលតែងតែបន្តគាំទ្រ និងចូលរួមចំណែកក្នុងការអភិវឌ្ឍរបស់ធនាគារ យើងខ្ញុំ និងសូមអរគុណដល់គណៈគ្រប់គ្រង បុគ្គលិកគ្រប់ជាន់ថ្នាក់ ដែលបន្តលះបង់ ខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដែលជាកត្តាជំរុញនាំឱ្យមាននូវសមិទ្ធផលជាច្រើន និងលទ្ធផលល្អប្រសើរក្នុងឆ្នាំ២០២១ នេះ។




**អ្នកឧកញ៉ា លី ហួរ**
**ប្រធានក្រុមប្រឹក្សាភិបាល**

# ១.៥ ចំណាប់អារម្មណ៍របស់អគ្គនាយកស្តីទី




នៅក្នុងបរិបទនៃការរីករាតត្បាតនៃជំងឺកូវីដ-១៩វិស័យធនាគារកម្ពុជាត្រូវបានមើលឃើញថានៅតែមានភាពរីកចម្រើនយ៉ាងរឹងមាំ ហើយធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ហៅកាត់ថា "ធនាគារ" ក៏ទទួលបានសមិទ្ធផលវិជ្ជមាន និងមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរក្នុងឆ្នាំ២០២១។

ឆ្នាំ២០២១ គឺជាឆ្នាំមួយដែលប្រទេសកម្ពុជា និងធនាគារសម្របខ្លួនទៅនឹងជំងឺកូវីដ-១៩បើទោះជាមានការរីករាលដាលនៃជំងឺនេះជាបន្តបន្ទាប់ក៏ដោយ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សានិរន្តរភាពសកម្មភាពអាជីវកម្ម នៅក្នុងប្រទេស រាជរដ្ឋាភិបាលបានធ្វើយុទ្ធនាការចាក់វ៉ាក់សាំងប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងនូវភាពសាំនៅក្នុងសហគមន៍ បន្ធូរបន្ថយការរឹតបន្តឹងនៃការធ្វើដំណើរ និងដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ចឡើងវិញ។ ខណៈពេលនោះផងដែរ ធនាគារនូវតែបន្តផ្តល់សេវាកម្មហិរញ្ញវត្ថុជូនដល់អតិថិជនយ៉ាងរលូន និងបន្តការរីកចម្រើនគួរឱ្យកត់សម្គាល់ទៅលើ ប្រាក់កម្ចី ប្រាក់បញ្ញើ ទ្រព្យសកម្ម និងចំនួនអតិថិជន តាមរយៈសាខារបស់ខ្លួនទូទាំងប្រទេស ប្រព័ន្ធធនាគារចល័តម៉ាស៊ីនអេធីអឹមនិងភ្នាក់ងារលីហួរវេរលុយចំនួន៤៥០០កន្លែង ដែលអនុលោម ទៅតាមការអនុវត្តយ៉ាងមានប្រសិទ្ធភាព ទៅលើផែនការអាជីវកម្មដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងភាគទុនិក។

នៅក្នុងបរិបទដែលមានផលប៉ះពាល់ពី ជំងឺរាតត្បាតកូវីដ-១៩ យើងសង្កេតឃើញមាន ឥណទានរៀបចំឡើងវិញចំនួន ៥.៥ពាន់លានដុល្លារអាមេរិក។ ទោះបីជាយ៉ាងណាក៏ដោយវិស័យធនាគារទាំងមូលនៅតែត្រូវបានមើលឃើញពីសន្ទុះនៃការកើនឡើងនៃប្រាក់កម្ចី និងប្រាក់បញ្ញើក្នុងឆ្នាំ២០២១។

យោងទៅតាម របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ផលប័ត្រឥណទានបានកើនឡើង ២១,២% មានចំនួន ៤៥.៧ពាន់លានដុល្លារអាមេរិកធៀបនឹងឆ្នាំមុនស្របពេលដែលប្រាក់បញ្ញើអតិថិជនកើនឡើង១៥,៤%មានចំនួន ៣៨.៥ពាន់លានដុល្លារអាមេរិក។

ចំណែកឯឥណទានដែលមិនដំណើរការវិញ គឺស្ថិតនៅក្នុងកម្រិត ២,៤%។ ស្របពេលគ្នានេះដែរ ធនាគារសម្រេចបាននូវលទ្ធផលវិជ្ជមាន និងបន្តហិរញ្ញវត្ថុល្អ ក្នុងឆ្នាំ២០២១៖

- ផលប័ត្រឥណទានឈានទៅដល់ ៤៩៩លានដុល្លារអាមេរិក ឬដែលកើនឡើង ១៩៥% ពីឆ្នាំ២០២០។
- ប្រាក់បញ្ញើបានកើនឡើងដល់ ៤៤៤លានដុល្លារអាមេរិកឬស្មើនឹង២៧០%។
- ទ្រព្យសកម្មសរុបកើនឡើងដល់ ១៩៥% បើធៀបទៅនឹងឆ្នាំ២០២០ និងឈានដល់ ៦២២.៧លានដុល្លារអាមេរិក។
- ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធរួច មានចំនួន ៦.១២លានដុល្លារអាមេរិក។
- ឥណទានដែលមិនដំណើរការស្ថិតក្នុងអត្រាដែលគ្រប់គ្រងបានគឺ០,៦៩%។
- មានចំនួនបុគ្គលិកសរុប ១.៤៣៤នាក់ ដែលកើនឡើង ២៤% ធៀបនឹងឆ្នាំមុន។

មិនត្រឹមតែជាសមិទ្ធផលហិរញ្ញវត្ថុប៉ុណ្ណោះទេ ធនាគារក៏បានបន្តអភិវឌ្ឍ នូវផលិតផលនិងសេវាកម្មផ្សេងៗតាមរយៈការដាក់ប្រើប្រាស់នូវសេវាកម្មភតិសន្យាហិរញ្ញវត្ថុដែលជាផលិតផលសំខាន់មួយក្នុងចំណោមផលិតផលទាំងអស់របស់ធនាគារ ហើយនេះក៏ជាការរួមចំណែកលើកកម្ពស់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាក៏ដូចជាវិស័យសេដ្ឋកិច្ចរបស់ប្រទេសទាំងមូលផងដែរ។ ក្រៅពីនេះ ដោយមានការគាំទ្រ និងអនុម័តពីធនាគារជាតិនៃកម្ពុជា និង និយ័តករមូលបត្រកម្ពុជា ធនាគារបានបោះផ្សាយមូលបត្របំណុលជាឯកជនទៅកាន់អ្នកវិនិយោគគិននៅក្រៅប្រទេសដែលមានសក្តានុពលសម្រាប់ការប្រមូលមូលនិធិដើម្បីគាំទ្រដល់ផលប័ត្រប្រាក់កម្ចីរបស់ធនាគារ។

គួរកត់សម្គាល់ថាការបោះផ្សាយមូលបត្របំណុលជាឯកជននេះគឺជាយុទ្ធសាស្ត្រដ៏ល្អសម្រាប់ធនាគារក្នុងការទទួលបានមូលនិធិដែលមានតម្លៃទាបពីធនធានហិរញ្ញវត្ថុអន្តរជាតិដើម្បីគាំទ្រដល់ផលប័ត្រប្រាក់កម្ចីរបស់ធនាគារ។ លើសពីនេះទៅទៀត សេវាកម្មហិរញ្ញវត្ថុឌីជីថលរបស់ធនាគារ និងភ្នាក់ងារលី ហួរ វេលុយ បានដើរតួយ៉ាងសំខាន់ក្នុងការរក្សានិរន្តរភាពអាជីវកម្មរបស់ធនាគារក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។
ជាផែនការនាពេលខាងមុខនិងស្របទៅតាមផែនការស្តារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០២២ អាជីវកម្មរបស់យើងនឹងផ្តោតសំខាន់ទៅលើការពង្រឹងប្រព័ន្ធឌីជីថលដែលមានស្រាប់និងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗតាមរយៈប្រព័ន្ធធនាគារចល័ត និងប្រព័ន្ធធនាគារអ៊ីនធឺណិត និងមធ្យោបាយឌីជីថលផ្សេងៗទៀតដើម្បីផ្តល់ជូនអតិថិជននូវបទពិសោធន៍សេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុត។ ទន្ទឹមនឹងនេះផងដែរ ធនាគារក៏មានគម្រោងក្នុងការពង្រីក និងផ្លាស់ប្តូរទីតាំងសាខាមួយចំនួន ដើម្បីពង្រឹងនូវវិសាលភាព និងកេរ្តិ៍ឈ្មោះរបស់ធនាគារបន្ថែមពីលើសាខាធនាគារដែលមានស្រាប់ក្នុង២៥ខេត្តក្រុង។ ធនាគារនឹងបន្ថែមចំនួន ម៉ាស៊ីនអេធីអឹម និងបន្តការអភិវឌ្ឍផលិតផល និងសេវាកម្មរបស់ធនាគារ ឱ្យកាន់តែប្រសើរថែមទៀត ដោយមានការចូលរួមជាមួយដៃគូអាជីវកម្មដែលមានសក្តានុពល និងបណ្តាភាគីពាក់ព័ន្ធដើម្បីបំពេញតម្រូវការទីផ្សារក្នុងឆ្នាំ២០២២។ យើងជឿជាក់ថាតាមរយៈការបន្តធ្វើឱ្យប្រសើរឡើងនិងធ្វើបច្ចុប្បន្នភាពសេវាកម្មហិរញ្ញវត្ថុឌីជីថលរបស់ធនាគារ ធនាគារនឹងអាចធានាបាននូវសុវត្ថិភាពខ្ពស់ ការផ្តល់សេវារហ័ស និងផ្តល់ជូននូវតម្លៃប្រកួតប្រជែងនៅក្នុងទីផ្សារ។

តាំងនាមឱ្យគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ សូមធ្វើការថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូនដល់ភាគទុនិក ប្រធានក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាភិបាល សម្រាប់ការគ្រប់គ្រង និងគាំទ្រដល់ប្រតិបត្តិការរបស់ធនាគារ។ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា អាជ្ញាធរ ភាគីពាក់ព័ន្ធ និងអតិថិជនសម្រាប់ការផ្តល់ទំនុកចិត្ត ការគាំទ្រ និងការសហការចំពោះកិច្ចប្រតិបត្តិការរបស់ធនាគារ។ បើគ្មានការគាំទ្រនិងការចូលរួមទាំងអស់នេះទេធនាគារនឹងមិនអាចសម្រេចបាននូវការងារដ៏ជោគជ័យ ដែលគួរឱ្យកត់សម្គាល់បែបនេះ ក្នុងឆ្នាំ២០២១ នោះទេ។




**លោក ម៉ៅ ប៊ុនឡូ**
**អគ្គនាយកស្តីទី**

# ១.៦ ក្រុមប្រឹក្សាភិបាល



**អ្នកឧកញ៉ា លី ហួរ**

ប្រធានក្រុមប្រឹក្សាភិបាល



**លោក MAKOTO MIYAZAKI**

សមាជិកក្រុមប្រឹក្សាភិបាល

អ្នកឧកញ៉ា លី ហួរ ជាស្ថាបនិកនៃសម្ព័ន្ធ លី ហួរ គ្រុប កើតនៅឆ្នាំ១៩៥៤ មានទីកន្លែងកំណើតនៅខេត្តកំពង់ចាម។ លោកចាប់ ផ្តើមសម្ព័ន្ធអាជីវកម្មរបស់លោកពីមាសចំនួន ២ (ពីរ) ជី កន្លះ នៅដើមទសវត្សន៍៨០ ក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សព្វថ្ងៃនេះអ្នកឧកញ៉ា លី ហួរ គឺជាពាណិជ្ជករដ៏លេចធ្លោ និងគួរឱ្យទុកចិត្តបំផុតនៅប្រទេសកម្ពុជា។ នៅពីក្រោមចក្ខុវិស័យនៃភាពដឹកនាំរបស់ អ្នកឧកញ៉ា លី ហួរ ក្រុមហ៊ុន លី ហួរ គ្រុបបានអភិវឌ្ឍនូវមុខជំនួញហិរញ្ញវត្ថុជាច្រើនរួមមាន ក្រុមហ៊ុនប្តូរប្រាក់ ក្រុមហ៊ុនជួញដូរមាស ក្រុមហ៊ុនបញ្ចាំ ធនាគារពាណិជ្ជ ក្រុមហ៊ុនភតិសន្យា ក្រុមហ៊ុនផ្ញើលុយក្នុង និងក្រៅប្រទេស ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនគ្រប់គ្រង ការវិនិយោគជាដើម។ អាជីវកម្មផ្សេងទៀតរបស់អ្នកឧកញ៉ាមានដូចជា ក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ ក្រុមហ៊ុនដាំដុះចំការកៅស៊ូ និងស្វាយចន្ទី។ ភាពជោគជ័យរបស់ក្រុមហ៊ុន ក៏ដូចជាការគាំទ្រទាំងឡាយពីដៃគូពាណិជ្ជកម្ម និងសាធារណៈជន បានមកពីភាពសុច្ចរិត ស្មោះត្រង់ តម្លាភាព និងការអនុវត្តដោយប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ជាចម្បងរបស់ក្រុមហ៊ុន លី ហួរ គ្រុប។ ក្រុមហ៊ុន លី ហួរ គ្រុប បាននឹងកំពុងចូលរួមចែករំលែកនៅក្នុងភាពរីកចម្រើននៃវិស័យសេដ្ឋកិច្ចរបស់ប្រទេស កម្ពុជា តាមរយៈក្រុមហ៊ុនចម្រុះដ៏ធំរបស់ខ្លួន។ ជាក់ស្តែង អ្នកឧកញ៉ា លី ហួរ បានទទួលនូវពានរង្វាន់ មេដាយ និងការទទួលស្គាល់ជាច្រើនពីការចូលរួមចំណែករបស់អ្នកឧកញ៉ាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

លោក Makoto Miyazaki មានបទពិសោធន៍ជាង២០ឆ្នាំក្នុងការដឹកនាំគ្រប់គ្រងជាន់ខ្ពស់នៅក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនដ៏ធំនេះ ហើយសព្វថ្ងៃនេះ លោកជានាយកប្រតបត្តិមួយរូបនៃក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង ដោយមានតួនាទីដឹកនាំនាយកដ្ឋានគ្រប់គ្រង ពាណិជ្ជកម្មក្រៅប្រទេស។ លោកក៏កាន់នូវតួនាទីធំៗ មួយចំនួនទៀតដែរ ដូចជា អភិបាល អភិបាលមិនប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាន (President) នៃក្រុមហ៊ុនធំៗ ផ្សេងៗទៀត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង។ លោក Miyazaki មានតួនាទីជាអភិបាល នៅតាមបណ្តាក្រុមហ៊ុនសម្ព័ន្ធ និងក្រុមហ៊ុនវិនិយោគផលប័ត្រជាច្រើនទៀត។ លោក Miyazaki បានចាប់ផ្តើមអាជីពការងារដំបូងរបស់គាត់ជាមួយក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីងជានាយកប្រតិបត្តិប្រចាំការិយាល័យ តំណាងទីក្រុងប៉េកាំងកាលពីឆ្នាំ២០០៥ រហូតដល់ ឆ្នាំ២០១២។ បន្ទាប់មកលោក ក៏ត្រូវបានតែងតាំងជានាយកប្រតិបត្តិដឹកនាំនាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេសរហូតមកដល់សព្វថ្ងៃនេះ។ នាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេស គឺជានាយកដ្ឋាន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍ របស់បណ្តាក្រុមហ៊ុនសម្ព័ន្ធទាំងឡាយដែលមានអាជីវកម្មចម្រុះមានតាំងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនបណ្តាក់ទុនសាជីវកម្ម (Corporate Venture Capital) និងក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មជាដើម ដែលមានទីតាំងនៅក្រៅប្រទេសជប៉ុន រួមមានប្រទេសអាល្លឺម៉ង់ ហុងកុង ម៉ាឡេស៊ី សាធារណរដ្ឋប្រជាមាណិត្យចិន សិង្ហបុរី កូរ៉េខាងត្បូង ថៃ សហរដ្ឋអាមេរិក និងវៀតណាម។ លោក Miyazaki គឺជាអតីតនិស្សិតនៃសាកលវិទ្យាល័យ Western Oregon University នៃសហរដ្ឋអាមេរិក (ពីមុនត្រូវបានគេស្គាល់ជា Western Oregon State College) ជាកន្លែងដែលលោកបានទទួលនូវបរិញ្ញាប័ត្រផ្នែកធុរៈកិច្ច។



## ឧកញ៉ា លី សុភាព

សមាជិកក្រុមប្រឹក្សាភិបាល

ឧកញ៉ា លី សុភាព មានបទពិសោធន៍ក្នុងតំណែងជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ជាច្រើនដូចជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន លី ហួរ ផេប្រូ ភីអិលស៊ី ចាប់តាំងពីឆ្នាំ២០១៦។ ជាមួយគ្នានោះ លោកឧកញ៉ា លី សុភាព ត្រូវបានតែងតាំងដោយ អ្នកឧកញ៉ា លី ហួរ ដែលជាម្ចាស់ក្រុមហ៊ុន លី ហួរ អ៊ិចឆេង ឯ.ក និង រតនៈអាលាំងកា (Rattanak Alangka) ជាអគ្គនាយកប្រតិបត្តិតាំងពីឆ្នាំ២០០៧។ លោកក៏មានអាជីវកម្មមួយចំនួនដូចជា អាយ ខេ វី អិម ឌីស្ទ្រីប៊្យូសិន ចែកចាយអាហារ នៅក្នុងឆ្នាំ ២០០៨ និង ក្រុមហ៊ុន អាយ.ជី. ខនសាល់ធេន ក្រុមហ៊ុនផ្តល់សេវាធនធានមនុស្សនៅក្នុងឆ្នាំ ២០០៩។ ឧកញ៉ា លី សុភាព បានទទួលសញ្ញាប័ត្រគណនេយ្យនៅឆ្នាំ ១៩៩៩ ពីប្រទេស សិង្ហបុរី។ លោកក៏ទទួលបាន បរិញ្ញាប័ត្រកិត្តិយសផ្នែកពហុរចនាប្រព័ន្ធផ្សព្វផ្សាយ ពីសាកលវិទ្យាល័យ Huddersfield ក្នុងទីក្រុង Manchester នៃចក្រភពអង់គ្លេសឆ្នាំ ២០០៤។



## លោក Shuzo Shikata

សមាជិកក្រុមប្រឹក្សាភិបាល

លោក Shuzo Shikata ត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាភិបាល និងជាអភិបាលប្រតិបត្តិរបស់ធនាគារ។ លោកក៏ជាអ្នកតំណាងភាគទុនិកនៃក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង ដែលមានអាសយដ្ឋាននៅទីក្នុង ក្រុងតូក្យូ ប្រទេសជប៉ុន។ សព្វថ្ងៃនេះ លោកកំពុងបម្រើការងារជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ Tien Phong Commercial Bank នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ លោក Shikata ធ្លាប់ធ្វើការនៅធនាគារដ៏ធំមួយឈ្មោះធនាគារ MUFG នៅក្នុងទីក្រុង តូក្យូ ប្រទេសជប៉ុន មុនពេលលោកចូលបម្រើការងារ នៅប្រទេសកម្ពុជា និងប្រទេសវៀតណាម។

ក្នុងនាមជាអ្នកឯកទេសក្នុងវិស័យសាជីវកម្ម និងធនាគារវិនិយោគ គាត់បានចូលរួមកាន់តួនាទីសំខាន់ៗ ជាច្រើននៅក្នុងការពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អ និងការគ្រប់គ្រងឱ្យមានតម្លាភាពនៅក្នុង ធនាគារ អេស ប៊ី អាយ លី ហួរ។ ដោយមានបទពិសោធន៍យ៉ាងច្រើននៅក្នុងការដឹកនាំគ្រប់គ្រងធនាគារនៅបរទេស ខ្លួនលោកផ្ទាល់ ព្រមទាំងក្រុមហ៊ុន SBI Holdings Inc. បាននឹងកំពុងជួយជ្រោមជ្រែងដល់ធនាគារក្នុងការរៀបចំ និងអនុវត្តនូវយុទ្ធសាស្រ្តសាជីវកម្មរបស់ធនាគារ។ លោក Shikata បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Ritsumeikanនៃប្រទេសជប៉ុន។



## លោក Eiichiro So

**សមាជិកក្រុមប្រឹក្សាភិបាល**



## លោក ខែក វ៉ារី

**សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ**

លោក Eiichiro So បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលកាលពីខែធ្នូ ឆ្នាំ២០១៩។ លោកបានធ្វើការជាមួយក្រុមហ៊ុន SBI Group អស់រយៈពេលជាង ១៥ឆ្នាំ ហើយសព្វថ្ងៃនេះ លោកជាសហនាយកប្រតិបត្តិ ជានាយកប្រតិបត្តិជាន់ខ្ពស់ និងអនុប្រធាននៃក្រុមហ៊ុន SBI Investment Korea Co., Ltd., ដែលជាក្រុមហ៊ុនបណ្តាក់ដើមទុនសាជីវកម្ម (listed venture capital firm) ដែល បានចុះបញ្ជីក្នុងផ្សារភាគហ៊ុននៅទីផ្សារភាគហ៊ុនកូរ៉េឈ្មោះ KOSDAQ (Korean Securities Dealers Automated Quotations) ជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន SBI Royal Security Plc. ជាអភិបាលធនាគារ Tien Phong Commercial Joint Stock Bank (នៅប្រទេសវៀតណាម) និងជាអភិបាលនៃក្រុមហ៊ុន SBI Thai Online Securities Col, Ltd (នៅប្រទេសថៃ)។ ជាមួយបទពិសោធន៍ជាង ២០ឆ្នាំ របស់លោកនៅក្នុងវិស័យធនាគារវិនិយោគ និងមូលធនឯកជន (private equity) ជាពិសេសបទពិសោធន៍នៅក្នុងទីផ្សារដែលកំពុងមានការរីកចម្រើនខ្លាំង (រួមមាន កូរ៉េខាងត្បូង សិង្ហបុរី វៀតណាម និងកម្ពុជា) ដោយផ្តោតទៅលើវិស័យហិរញ្ញវត្ថុ (រួមមាន ធនាគារ មូលបត្រ និងមូលធនឯកជន) លោកបានចូលរួមចំណែកយ៉ាងច្រើនទៅក្នុងការអភិវឌ្ឍអាជីវកម្ម និងបច្ចេកទេសគ្រប់គ្រងរបស់ធនាគារ។ ពីមុនមកលោកធ្លាប់ជាអនុប្រធាននៃធនាគារ Sumitomo Mitsui Banking Corporation ជាអភិបាលនៃធនាគារភ្នំពេញពាណិជ្ជ ជាអភិបាលប្រតិបត្តិនៃ ក្រុមហ៊ុន SBI Ven Capital Pte. Ltd (ប្រទេសសិង្ហបុរី) និងជាអភិបាលនៃ ក្រុមហ៊ុន FPT Securities (ប្រទេសវៀតណាម)។

លោក So បានបញ្ចប់ការសិក្សាកម្រិតថ្នាក់អនុបណ្ឌិតមកពីសាកលវិទ្យាល័យ Hitotsubashi ថ្នាក់ក្រោយឧត្តមសិក្សា នៃនាយកដ្ឋានយុទ្ធសាស្ត្រសាជីវកម្មអន្តរជាតិរបស់ ប្រទេសជប៉ុន និងបរិញ្ញាប័ត្រផ្នែកគណនេយ្យមហាវិទ្យាល័យពាណិជ្ជកម្មពីសាកលវិទ្យាល័យChuo (ប្រទេសជប៉ុន)។

លោក ខែក វ៉ារី ត្រូវបានតែងតាំងជាអភិបាលឯករាជ្យ នៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ បច្ចុប្បន្ននេះ លោកគឺជាមេធាវី និងជាស្ថាបនិកនៃការិយាល័យមេធាវី DBLS Law ហើយក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន RGL Equity (Siemreap) Co. Ltd., ជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដែលជាក្រុមហ៊ុនសម្ព័ន្ធរបស់ក្រុមហ៊ុន Goodland Group (ជាក្រុមហ៊ុនចុះក្នុងបញ្ជីក្នុងផ្សារភាគហ៊ុនរបស់ប្រទេសសិង្ហបុរី)។ លោកគឺជាអតីតអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជានៅចន្លោះ ឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៤។ លោក ខែក វ៉ារី ត្រូវបានជ្រើសតាំងឱ្យក្លាយជាប្រធានសហព័ន្ធកីឡាបាល់ទាត់កម្ពុជាផងដែរ។ ក្នុងអំឡុងពេលនោះ លោកក៏បានបំពេញការងារជាសមាជិកគណៈកម្មាធិការបណ្តឹងឧទ្ធរណ៍របស់សហព័ន្ធបាល់ទាត់អន្តរជាតិហៅកាត់ថា FIFA។ នៅចន្លោះឆ្នាំ ១៩៨៥ ដល់ ឆ្នាំ២០១៩ លោកបានកាន់តួនាទីសំខាន់ៗ មួយចំនួនដូចជា ជាភាគទុនិកជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល និងអភិបាលមិនប្រតិបត្តិនៅ តាមបណ្តាក្រុមហ៊ុនជាច្រើននៅប្រទេសបារាំង ប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាផងដែរ។



## លោក កែណែម វីដាណូ

**សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ**



## លោក ហួរ វរៈបុត្ត

**សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ**

លោក កែណែម វីដាណូ បានកើតនៅប្រទេសកម្ពុជាប៉ុន្តែបានចាកចេញទៅរស់នៅប្រទេសបារាំង ទីកន្លែង ដែលលោកបានចំណាយពេលវេលាប្រហែល ពីរទសវត្សន៍ដើម្បីសិក្សា និងទទួលបាន សញ្ញាប័ត្របីសំខាន់ៗគឺផ្នែកវិទ្យាសាស្រ្តនយោបាយ ផ្នែកសេដ្ឋកិច្ចនិងផ្នែកហិរញ្ញវត្ថុ និងធុរៈកិច្ច។ លោកបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ នៅកំឡុងពាក់កណ្តាល់ទសវត្សន៍ឆ្នាំ៩០ ដោយពាំនាំ នូវមហិច្ឆតាក្នុងការជួយកសាងប្រទេសកម្ពុជាដោយបានចូលបម្រើការងារប៉ុន្មានឆ្នាំដំបូងជាមួយ ក្រុមហ៊ុនសវនកម្មអន្តរជាតិ ហើយក្រោយមកលោកបានចំណាយពេលវេលាប្រហែល ២០ ឆ្នាំ ដោយកាន់តួនាទីនាយកប្រតិបត្តិផ្សេងៗដូចជារដ្ឋលេខាធិការ អគ្គនាយកនៃនាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកសង្វាក់ផ្គត់ផ្គង់ និងផលិតកម្ម នៅក្នុងគម្រោងអភិវឌ្ឍន៍ដែលឧបត្ថម្ភដោយ សហភាព អឺរ៉ុប ដើម្បីជួយដល់អាជីវកម្មបែបសង្គមកិច្ច ដែលបានផ្តល់ការងារដល់ពលរដ្ឋកម្ពុជា ប្រមាណ ជិត ១.២០០ នាក់ ព្រមទាំងថ្នាក់ដឹកនាំផ្សេងៗទៀតដែលស្ថិតនៅក្នុងវិស័យនោះ។

សព្វថ្ងៃនេះ លោក ហួរ វរៈបុត្ត គឺជាសាស្រ្តាចារ្យនៅសាលារៀន CamEd Business School និងជាសមាជិកក្រុមប្រឹក្សាភិបាល/រតនាភិបាលរបស់សមាគម Eurocham Cambodia។ លោកមានបទពិសោធន៍ការងារជាង ២៥ឆ្នាំ នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុទាំងក្នុងតំបន់ អឺរ៉ុប និងអាស៊ីប៉ាស៊ីហ្វិក។ លោកជាអតីតអភិបាលនៃក្រុមហ៊ុន The Blue Circle និងធ្លាប់ជាអ្នក គ្រប់គ្រងទូទៅនៅសមាគមធនាគារនៅកម្ពុជា (ហៅកាត់ថា IBF) លោកក៏ធ្លាប់បម្រើការងារនៅ ស្ថាប័នហិរញ្ញវត្ថុធំៗនៅអឺរ៉ុបមានដូចជា Credit Suisse (ចំនួន ១២ឆ្នាំ) ក្រុមហ៊ុនគ្រប់គ្រងទ្រព្យ សកម្ម Aberdeen Asset Management ក្រុមហ៊ុនធានារ៉ាប់រង AXA និងក្រុមហ៊ុន Banque Hottinguer។ លោកមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិតមកពីសាលាពាណិជ្ជកម្ម Chicago Booth school of Business (ឆ្នាំ២០១២)។ លោក ហួរ វរៈបុត្ត គឺជាអ្នកវិភាគហិរញ្ញវត្ថុដែល ទទួលស្គាល់ដោយសហភាពអឺរ៉ុប ពីសាលាឈ្មោះ The European Federation of Financial Analyst Societies – EFFAS ហើយថ្មីៗនេះ លោកបានទទួលវិញ្ញាបនបត្រ វគ្គសិក្សាអភិបាលសាជីវកម្ម (ឆ្នាំ២០២០) ពីសាកលវិទ្យាល័យ Harvard Business School ផងដែរ។

# ១.៧ គណៈគ្រប់គ្រងជាន់ខ្ពស់



## លោក ម៉ៅ ប៉ូឡូ

**អគ្គនាយកស្តីទី**

*តែងតាំង ចាប់ពី ខែមីនា ឆ្នាំ២០២២

លោក ម៉ៅ ប៉ូឡូ បានចូលបំរើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី តួនាទីជា អគ្គនាយករង និងជានាយកប្រតិបត្តិហានិភ័យ ចាប់តាំង ពីឆ្នាំ២០១២។ លោកគឺជានិស្សិតអាហារូបករណ៍ ដែលបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ក្នុងឆ្នាំ១៩៩៩ ពីសាកលវិទ្យាល័យ ជាតិគ្រប់គ្រង។ បន្ទាប់មកនៅឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងទូទៅពីសាកលវិទ្យាល័យប្រេសស្តុន នៅសហរដ្ឋអាមេរិក (ជាមហាវិទ្យាល័យពាណិជ្ជសាស្រ្ត និងគ្រប់គ្រងរដ្ឋបាល) ដែលទទួលស្គាល់ដោយរដ្ឋ Wyoming សហរដ្ឋអាមេរិច។ លោកមានបទពិសោធន៍ជិត ២០ឆ្នាំ ក្នុងការគ្រប់គ្រង រដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងការគ្រប់គ្រងផលប័ត្រឥណទាន ទាំងនៅក្នុងអង្គការអន្តរជាតិធំៗ និងគ្រឹះស្ថានធនាគារ ដូចជាធនាគារ ANZ Royal ជាដើម។ ក្នុងអាជីពការងារជាមួយធនាគារ ANZ Royal លោកធ្លាប់ធ្វើជា ប្រធានគ្រប់គ្រងហានិភ័យឥណទាន ដែលមានសិទ្ធិអនុម័ត សំណើឥណទានរបស់អតិថិជនក្នុងមួយនាក់រហូតដល់ ទៅទឹកប្រាក់ ២លាន ដុល្លារអាមេរិក មុនពេលដែលលោកត្រូវបានតំឡើងឋានៈជា នាយកឥណទានបុគ្គល ដែលគ្រប់គ្រងឥណទានគេហដ្ឋាន និងឥណទានអាជីវកម្មខ្នាតតូច និងមធ្យម។





# ឧកញ៉ា លី សុភាព

## អគ្គនាយករង

ឧកញ៉ា លី សុភាព មានបទពិសោធន៍ក្នុងតំណែងជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ជាច្រើនដូចជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន លី ហួរ ផេប្រូភីអិលស៊ី ចាប់តាំងពីឆ្នាំ២០១៦។ ជាមួយគ្នានោះ លោកឧកញ៉ា លី សុភាព ត្រូវបានតែងតាំងដោយ អ្នកឧកញ៉ា លី ហួរ ដែលជាម្ចាស់ក្រុមហ៊ុន លី ហួរ អ៊ិចឆេង ឯ.ក និង រតនៈអាលាំងកា (Rattanak Alangka) ជាអគ្គនាយកប្រតិបត្តិតាំងពីឆ្នាំ២០០៧។ លោកក៏មានអាជីវកម្មមួយចំនួនដូចជា អាយ ខេវី អិម ឌីស្ទ្រីប៊្យូសិន ចែកចាយអាហារ នៅក្នុងឆ្នាំ ២០០៨ និង ក្រុមហ៊ុន អាយ.ជី. ខនសាល់ធេន ក្រុមហ៊ុនផ្តល់សេវាធនធានមនុស្ស នៅក្នុងឆ្នាំ ២០០៩។ ឧកញ៉ា លី សុភាព បានទទួលសញ្ញាប័ត្រគណនេយ្យនៅ ឆ្នាំ ១៩៩៩ ពីប្រទេសសិង្ហបុរី។ លោកក៏ទទួល បាន បរិញ្ញាប័ត្រកិត្តិយសផ្នែកពហុរចនាប្រព័ន្ធផ្សព្វផ្សាយ ពីសាកលវិទ្យាល័យ Huddersfield ក្នុងទីក្រុង Manchester នៃចក្រភពអង់គ្លេស ឆ្នាំ២០០៤ ។


VIP 2
VIP 3



# លោក ឡយ សារ៉េត

## អគ្គនាយករង

លោក ឡយ សារ៉េត មានបទពិសោធន៍ជាង ១៧ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ជានាយកប្រតិបត្តិអាជីវកម្មនៅចុងឆ្នាំ២០១៩ហើយបន្ទាប់មកត្រូវបានតែងតាំងជា អគ្គនាយករង នៅចុងខែមីនា ឆ្នាំ២០២២។ មុនពេលចូលបម្រើការងារជាថ្មីនៅ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក លោក ឡយ សារ៉េតធ្លាប់បម្រើការជានាយកប្រតិបត្តិជាន់ខ្ពស់ នៅតាមបណ្តាល គ្រឹះស្ថាន និងធនាគារជាច្រើនដូចជា៖ ធនាគារប្រៃសណីយ៍កម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ធនាគារ ANZ រ៉ូយ៉ាល់ និង អង្គការ UNDP។ បច្ចុប្បន្ន លោក ឡយសារ៉េត កំពុងសិក្សាលើជំនាញ Chartered Banker (CB)កម្រិត៣ ពីវិទ្យាស្ថាន Chartered Banker និង Asian Institute of Chartered Banker (AICB)។ លោកជាសមាជិកវិទ្យាស្ថានគណនេយ្យករគ្រប់គ្រងជំនាញ (CIMA) និងបានបញ្ចប់កំរិតគណនេយ្យករជំនាញសកល (CGMA) ពីចក្រភពអង់គ្លេស។ លោក ឡយ សារ៉េត ក៏ជាសមាជិក របស់វិទ្យាស្ថានគណនេយ្យករគ្រប់គ្រងជំនាញ និងបានបញ្ចប់កំរិត AMA ពីប្រទេសអូស្ត្រាលី។ លោក ឡយ សារ៉េត បានបញ្ចប់ថ្នាក់អនុបណ្ឌិតលើ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ពីសាកលវិទ្យាល័យវេទមហាឫស្សី។


VIP 1
VIP 2
VIP 3



## លោក នី ប្ញ៉ាត

**នាយកប្រតិបត្តិហិរញ្ញវត្ថុស្ដីទី**

លោកប្ញ៉ាត ធ្លាប់ជាសវនករនៅក្នុងក្រុមហ៊ុន KPMG ក្នុងប្រទេសកម្ពុជា និងមានបទពិសោធន៍សវនកម្មក្នុងវិស័យធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងវិស័យផ្សេងៗទៀតអស់រយៈ ពេល១៣ឆ្នាំ ដែលក្នុងនោះលោកធ្លាប់បានបម្រើការងារជាសនវករនៅក្រុមហ៊ុន KPMG ដែលមានការិល័យនាទីក្រុង Los Angeles សហរដ្ឋអាមេរិករយៈពេល១ឆ្នាំ និង ៦ខែ ផងដែរ។ ក្នុងកំឡុងពេលបម្រើការងារជាសវនករនៅក្រុមហ៊ុន លោកក៏មានតួនាទីជាអ្នកប្រឹក្សាយោបល់សម្រាប់គម្រោង IFRS វាយតម្លៃការគ្រប់គ្រងផ្ទៃក្នុង កំណត់ម៉ូឌែលហានិភ័យឥណទាន វិភាគស្ថានការណ៍ហិរញ្ញវត្ថុសម្រាប់ការរួមបញ្ចូលក្រុមហ៊ុន និងសម្រាប់ក្រុមហ៊ុនដែរចង់បោះផ្សាយមូលប័ត្រ។ លោកក៏បានបម្រើការក្នុងតួនាទីជារថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយទទួលខុសត្រូវយ៉ាងចម្បងក្នុងទំនាក់ទំនងអតិថិជន រៀបចំយុទ្ធសាស្រ្តអាជីវកម្ម គ្រប់គ្រងផែនការថវិការ និងវិភាគលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ។បើក្រឡេកទៅមើលកម្រិតវប្បធម៌លោកផ្ទាល់ លោកបានបញ្ចប់បរិញ្ញាប័ត្រជំនាញគ្រប់គ្រងអាជីវកម្ម នៅសកលវិទ្យាល័យបៀលប្រាយ។ លោកក៏ទទួលបានសញ្ញាប័ត្រជំនាញ Investment Foundation ពីវិទ្យាស្ថាន CFA នៅក្នុងខែកញ្ញា ឆ្នាំ២០២១ ។ បន្ថែមទៀតនោះ លោកក៏ជាសមាជិកនៃ Association of Chartered Certified Accountant ហៅកាត់ថា "ACCA" តាំងពីឆ្នាំ២០១៨ ផងដែរ ។ បច្ចុប្បន្នលោកកំពុងបន្តការសិក្សាជំនាញ Chartered Banker ក្នុងកម្រិតបញ្ចប់ទី៣ នៅវិទ្យាស្ថាន Chartered Banker ហៅកាត់ថា "CB" និង វិទ្យាស្ថាន Asian Institute of Chartered Banker ហៅកាត់ថា "AICB" ។





## លោក ផាត់ រតនា

### នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង

លោក ផាត់ រតនា បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ មុខដំណែងជានាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង ចាប់តាំងពី ខែមិថុនា ឆ្នាំ២០១៨។ លោក បានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ Charles Stuart នៃប្រទេសអូស្រ្តាលី។ លោកមានបទពិសោធន៍ជាង ២០ឆ្នាំ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងមុខតំណែងជាច្រើន ដូចជាសវនករផ្ទៃក្នុង បន្ទាប់មកលោកត្រូវបានតែងតាំងជា នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅក្នុង ខែឧសភា ឆ្នាំ១៩៩៩ និងត្រូវបានតែងតាំងជា នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមនៅខែឧសភា ឆ្នាំ២០១០។ លោកបានសម្រេចនូវសមិទ្ធិផលដ៏ល្អជាច្រើនក្នុងការបំពេញភារកិច្ចដូចជាការបង្កើតឱ្យមានជាតួនាទី និងដំណើរការប្រតិបត្តិសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងហានិភ័យនៅក្នុងស្ថាប័ន។


VIP 1
VIP 2
VIP 3



## លោក ចាប ចំណាប់

### នាយកប្រតិបត្តិព័ត៌មានវិទ្យា

លោក ចាប ចំណាប់ មានបទពិសោធន៍ព័ត៌មានវិទ្យាជាង ១៥ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ បទពិសោធន៍របស់លោកគឺទាក់ទងនឹងផ្នែកផ្សេងៗនៅក្នុងបច្ចេកវិទ្យាព័ត៌មាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ការគ្រប់គ្រងគម្រោង ប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធធនាគារចល័ត រួមទាំងសមត្ថភាពសំខាន់របស់លោកក្នុងការអនុវត្តគម្រោង និងភាពជាអ្នកដឹកនាំ។ លោក ចាប ចំណាប់ បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងបរិញ្ញាបត្រចំនួនពីរ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងគណនេយ្យ។





## លោក រស់ សុខា

**ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសេវាកម្មហិរញ្ញវត្ថុ**
**ឌីជីថល/ប្រតិបត្តិការធនាគារ និងបច្ចេកវិទ្យា**

លោក រស់ សុខា មានបទពិសោធន៍ជាង២០ឆ្នាំក្នុងវិស័យធនាគារ។ លោកបានចាប់ផ្តើមអាជីពជាមួយវិស័យធនាគារដំបូងនៅធនាគារ UCB ដោយធ្វើការគ្រប់គ្រងមជ្ឈមណ្ឌលប័ណ្ណអេឡិចត្រូនិចតាមរយៈការអនុវត្តប្រព័ន្ធ EMV (Europay, MasterCard and Visa)។ លោកបានចូលរួមជាមួយធនាគារ ANZ ក្នុងឆ្នាំ២០០៥ ដោយធ្វើការសហប្រតិបត្តិការជាមួយក្រុមការងារគំរោងប្រចាំតំបន់ដើម្បីដំណើរការប្រព័ន្ធធនាគារអេឡិចត្រូនិចសម្រាប់ តំបន់ទាំងមូលដោយធ្វើការបំលែង និងទំនើបកម្មវិស័យធនាគារ។ លោកក៏បានចូលក្នុងការជម្រុញការបំលែងខ្លួនក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារ និងប័ណ្ណអេឡិចត្រូនិច របស់ធនាគារ ANZ ក្នុងប្រទេសឡាវផងដែរ។ លោកក៏បានចូលរួមជាមួយធនាគារ FTB ក្នុងការដឹកនាំប័ណ្ណអេឡិចត្រូនិច និងធនាគារឌីជីថល មុនពេលលោកចូលរួមជាមួយធនាគារស្ថាបនា មានតួនាទីជា នាយកប្រតិបត្តិឌីជីថលក្នុងការដឹកនាំដំណាក់កាលធ្វើការបំលែងខ្លួនទៅជាធនាគារឌីជីថល។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតពីវិទ្យាស្ថានបច្ចេកទេសអាស៊ានប្រទេសថៃ និង សាកលវិទ្យាល័យ Ecole Supérieure de Commerce Nantes Atlantique (ESCNA) ប្រទេសបារាំង នៅឆ្នាំ១៩៩៩។



# ១.៨ រចនាសម្ព័ន្ធគណៈគ្រប់គ្រង




ជំនួយការ
ប្រធានក្រុមប្រឹក្សាភិបាល
គណៈកម្មការ
ត្រួតពិនិត្យហានិភ័យ
អគ្គនាយករង
អគ្គនាយករង
នាយកប្រតិបត្តិ ហិរញ្ញវត្ថុ
នាយកប្រតិបត្តិ
តំណាងភាគទុនិក
នាយកប្រតិបត្តិ
ធនធានមនុស្ស
នាយកប្រតិបត្តិ
ហានិភ័យ
នាយករងប្រតិបត្តិ
អាជីវកម្ម
នាយក នាយកដ្ឋាន
ទូទាត់អន្តរជាតិ
នាយក នាយកដ្ឋាន
ភតិសន្យា
នាយក នាយកដ្ឋាន
ធនាគារពាណិជ្ជកម្ម
នាយករងប្រតិបត្តិ
ហិរញ្ញវត្ថុ
នាយក នាយកដ្ឋាន
ហិរញ្ញវត្ថុ
នាយក នាយកដ្ឋាន
រតនាភិបាល
នាយក នាយកដ្ឋាន
រដ្ឋបាល
នាយក នាយកដ្ឋាន
ប្រាក់បញ្ញើ
នាយក នាយកដ្ឋាន
អភិវឌ្ឍន៍ធនាគារឌីជីថល
នាយក នាយកដ្ឋាន
ធនាគារព្រីមៀរ៍
នាយក នាយកដ្ឋាន
ទីផ្សារ និង ទំនាក់ទំនង
នាយក នាយកដ្ឋាន
លេខាធិការក្រុមហ៊ុន
ការិយាល័យផ្នែកច្បាប់
នាយក នាយកដ្ឋាន
ធនធានមនុស្ស
នាយក នាយកដ្ឋានបណ្តុះ
បណ្តាលនិងអភិវឌ្ឍន៍បុគ្គលិក
នាយក នាយកដ្ឋានទូទាត់
សំណង និងអត្ថប្រយោជន៍
នាយករងប្រតិបត្តិ
ហានិភ័យ
នាយក នាយកដ្ឋាន
ហានិភ័យឥណទាន
នាយក នាយកដ្ឋាន
សេវាកម្មឥណទាន
នាយក នាយកដ្ឋាន
ហានិភ័យប្រតិបត្តិការ
ការិយាល័យផ្នែក
ប្រតិបត្តិតាម

# ការគ្រប់គ្រងហានិភ័យ



# ១.៩ ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យដើរតួនាទីយ៉ាងសំខាន់នៅក្នុងធនាគារ ដែលក្រុមការងារកំពុងផ្តោត និងផ្តល់អាទិភាព ព្រោះវាជាកាតាលីករដែលជួយនាំស្ថាប័នទាំងមូលឆ្ពោះទៅរកភាពជោគជ័យ ក៏ដូចជារក្សាបាននូវនិរន្តរភាពយូរអង្វែង។ ដូច្នេះដើម្បីធានាបានថាមានការគ្រប់គ្រងហានិភ័យ ប្រកបដោយប្រសិទ្ធភាព ធនាគារបានអភិវឌ្ឍន៍នូវគោលការណ៍សំខាន់ៗដើម្បីទប់ស្កាត់ហានិភ័យដែលអាចកើតឡើង។តាមបច្ចេកទេសដើម្បីធានាបាននូវការអនុវត្តល្អបំផុត នៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ធនាគារបានកំណត់វិសាលភាពច្បាស់លាស់នៃការអនុវត្តការងារ និងទំនួលខុសត្រូវ។
ការគ្រប់គ្រងហានិភ័យត្រូវបានបែងចែកជា ០៣ កម្រិតដូចខាងក្រោម៖

១. មុខងារអាជីវកម្ម មានទំនួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណហានិភ័យ និងគ្រប់គ្រងហានិភ័យផ្ទាល់ពីប្រតិបត្តិការប្រចាំថ្ងៃក៏ដូចជាការអនុលោមតាមគោលការណ៍ណែនាំផ្ទៃក្នុង និងបទប្បញ្ញត្តិដែលត្រូវបានគេហៅថា ការការពារហានិភ័យកម្រិតទី០១។

២. មុខងារគ្រប់គ្រងហានិភ័យ មានទំនួលខុសត្រូវក្នុងការផ្តល់យោបល់ និងប្រឹក្សាផ្ទាល់ទៅកាន់ អ្នកការពារកម្រិតទី០១ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យនៅក្នុងធនាគារដែលត្រូវបានគេហៅថាការការពារហានិភ័យកម្រិត០២។

៣. មុខងារសវនកម្មមានទំនួលខុសត្រូវក្នុងការផ្តល់នូវការធានាឯករាជ្យអំពីប្រសិទ្ធភាពនៃអ្នកការពារកម្រិតទី០១ និងកម្រិតទី០២ ដែលត្រូវបានគេហៅថា ការការពារហានិភ័យកម្រិតទី០៣។ បច្ចុប្បន្ន ធនាគារកំពុងធ្វើការលើការបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យមួយចំនួនរួមទាំងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យគោលនយោបាយហានិភ័យប្រតិបត្តិការគោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុក៏ដូចជាគោលនយោបាយគ្រប់គ្រងហានិភ័យឥណទាន។ បន្ថែមពីលើនេះ ដើម្បីធានាឱ្យបានថាការអនុវត្តមានប្រសិទ្ធភាព ធនាគារមានវិធីសាស្ត្រជាប្រព័ន្ធក្នុងការគ្រប់គ្រងហានិភ័យ និងជួយដល់ក្រុមការងារក្នុងការស្វែងរកដំណោះស្រាយបានទាន់ពេលវេលា។ ធនាគារបានអនុវត្តដំណើរការទាំង០៤នៃការគ្រប់គ្រងហានិភ័យដូចជាការកំណត់អត្តសញ្ញាណការវិភាគ និងការវាយតម្លៃហានិភ័យ ការដោះស្រាយហានិភ័យ និងការគ្រប់គ្រង និងការត្រួតពិនិត្យហានិភ័យ។

នាយកដ្ឋានហានិភ័យប្រតិបត្តិការ ដើរតួនាទីយ៉ាងសកម្មក្នុងការកំណត់អត្តសញ្ញាណហានិភ័យណាមួយដែលពាក់ព័ន្ធនឹងការអនុវត្តរបស់បុគ្គលិកក៏ដូចជាដំណើរការ និងនីតិវិធីនៃនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត។ បន្ទាប់ពីហានិភ័យត្រូវបានកំណត់នោះការវាយតម្លៃក៏នឹងត្រូវបានធ្វើឡើងដើម្បីយល់ពីលទ្ធភាពនៃការកើតឡើង និងផលប៉ះពាល់ដែលអាចកើតឡើង។ ជំហាននេះ ការគ្រប់គ្រងហានិភ័យនឹងជួយធានាឱ្យមានភាពស៊ីសង្វាក់គ្នានៃការកំណត់អត្តសញ្ញាណ ហានិភ័យធានាឱ្យមានរបាយការណ៍ហានិភ័យត្រឹមត្រូវ និងទាន់ពេលវេលា និងការត្រួតពិនិត្យហានិភ័យក្នុងធនាគារ។

លើសពីនេះ ដើម្បីគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធិភាព ធនាគារបានបង្កើត អនុវត្តវិធីសាស្ត្រ និងរៀបចំផែនការក្នុងការដោះស្រាយហានិភ័យដែលសមស្រប និងអាចកាត់បន្ថយហានិភ័យ ដល់កម្រិតដែលអាចទទួលយកបានដូចជា៖ ការកាត់បន្ថយហានិភ័យការបញ្ចៀសហានិភ័យការផ្ទេរហានិភ័យ និងការទទួលយកហានិភ័យ។

ជាចុងក្រោយ ហានិភ័យឥណទាន គឺជាហានិភ័យមួយក្នុងចំណោមហានិភ័យដ៏ទៃទៀតដែលអាចជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ដំណើរការរបស់ធនាគាររយៈពេលវែងហើយអាចធ្វើឱ្យ ធនាគារមិនអាចសម្រេចបានតាមផែនការដែលបានកំណត់។ ហានិភ័យឥណទានកើតឡើងពី សកម្មភាពផ្តល់ប្រាក់កម្ចី និងបុរេប្រទានបន្ទាប់មកហានិភ័យឥណទាន ក៏អាចកើតចេញពីតារាងតុល្យការដូចជា កិច្ចការសន្យាខ្ចីប្រាក់ជាដើម។ ដូច្នេះហើយហានិភ័យឥណទានត្រូវ បានដាក់បញ្ចូលក្នុងគោលនយោបាយឥណទានដើម្បីធានាថា ប្រតិបត្តិការធនាគារកំពុងដំណើរការយ៉ាងរលូន និងអាចគ្រប់គ្រងហានិភ័យបានក្នុងរយៈពេលវែង។

គណៈកម្មការគ្រប់គ្រងហានិភ័យដែលមានការគាំទ្រយ៉ាងខ្លាំងពីគណៈកម្មាធិការគ្រប់គ្រងហានិភ័យ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងហានិភ័យដែលអាចកើតឡើងផងដែរ។

គណៈកម្មការត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើហានិភ័យ ដែលអាចកើតមានក្នុងធនាគារ និងពិនិត្យមើលប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរៀបចំឡើងដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។
តាមបច្ចេកទេស កម្រិតទទួលយកហានិភ័យ ត្រូវបានកំណត់យ៉ាងច្បាស់សម្រាប់អាជីវកម្មជាពិសេសដែនកំណត់ផលិតផល លក្ខណៈវិនិច្ឆ័យផលិតផល និងលក្ខខ័ណ្ឌផលិតផលដូច្នេះបុគ្គលិកទាំងអស់មានភាពច្បាស់លាស់ និងងាយស្រួលក្នុងការអនុវត្ត។ ជាងនេះទៅទៀត ហានិភ័យទាំងអស់ក៏ត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាថាអ្វីដែលបានកំណត់ ឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែង នៃស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេស។

# ធនធានមនុស្ស



# ១.១០ ធនធានមនុស្ស

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាធនាគារពាណិជ្ជ ដែលទើបនឹងផ្លាស់ប្តូរថ្មីក្នុងអំឡុងពេលដែលស្ថាប័នហិរញ្ញវត្ថុទាំងអស់នៅលើពិភពលោកកំពុងប្រឈមមុខនឹងបញ្ហានៃជំងឺរាតត្បាត កូវីដ-១៩។ ធនាគារបានផ្តោតទៅលើការជំរុញការអនុវត្តវប្បធម៌ គុណភាព និងបន្តធ្វើឱ្យប្រសើរឡើង។ យើងផ្តល់តម្លៃដល់ភាពចម្រុះ និងផ្តល់ជូនប្រជាជនរបស់យើងម្នាក់ៗនូវឱកាសស្មើៗគ្នា ក្នុងការបន្តនូវការទទួលខុសត្រូវខ្ពស់ ហើយយើងមាននូវមោទនភាពដែលមានជនជាតិខ្មែរយើងមានការអភិវឌ្ឍ និងរីកចម្រើនជាលំដាប់ពីតួនាទីតូចតាចក្នុងអំឡុងពេលមីក្រូហិរញ្ញវត្ថុរហូតដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ និងប្រធាននាយកដ្ឋាននាពេលបច្ចុប្បន្ន។

នៅធនាគារ បុគ្គលិករបស់យើងគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់យើង និងជាសសរដ៏រឹងមាំក្នុងការគាំទ្រនិងជំរុញភាពជោគជ័យនៃអាជីវកម្មធនាគារនាពេលបច្ចុប្បន្ននេះ។ យើងផ្តល់តម្លៃ និងទទួលយកនូវភាពចម្រុះនៃបុគ្គលិកនៅក្នុងទីកន្លែងការងារហើយយើងកំពុងអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករបស់យើងដើម្បីឱ្យយើងអាចភ្ជាប់ទំនាក់ទំនងកាន់តែប្រសើរជាមួយអតិថិជនគោលដៅ និងផ្តល់នូវផលិតផល និងសេវាកម្មធនាគាររបស់យើងដោយជោគជ័យ។ យើងកំពុងផ្តោតលើការជម្រុញនៃការអនុវត្ត ការកែលម្អជាបន្តបន្ទាប់ និងគុណភាពនៃការផ្តល់សេវាកម្ម។ នៅចុងខែធ្នូ ឆ្នាំ២០២១ ចំនួននិយោជិតបានកើនឡើងពី ១.១៥៧ នាក់ក្នុងឆ្នាំ ២០២០ ដល់ ១.៤៣៤ នាក់ (៣៤៦ ជាបុគ្គលិកស្រី) និងចំនួនបុគ្គលិកថ្មីគឺប្រហែល ៦៣២នាក់ ក្នុងឆ្នាំនេះ។

មុខតំណែងភាគច្រើនដែលត្រូវបានជ្រើសរើសនៅតែផ្តោតលើមុខតំណែងជួរមុខ ទាំងការបង្កើនចំនួនបុគ្គលិកដែលមានស្រាប់ ឬជំនួសបុគ្គលិកដែលបានលាលែងពីធនាគារ។ ផ្នែកធនធានមនុស្ស បានផ្តោតលើដំណើរការត្រួតពិនិត្យឡើងវិញនូវគុណភាពនៃការផ្តល់សេវាការរៀបចំផែនការធនធានមនុស្សជាយុទ្ធសាស្ត្រការអភិវឌ្ឍ និងការដាក់ពង្រាយដើម្បីធានាថាដំណើរការគ្រប់គ្រងធនធាន និងការអភិវឌ្ឍបន្តដំណើរការទៅដោយរលូនដើម្បីគាំទ្រយ៉ាងរឹងមាំដល់ប្រតិបត្តិការអាជីវកម្ម។

ការគាំទ្រដល់ការកសាងសមត្ថភាពធនធានមនុស្ស យើងបានផ្តល់ឱកាសសិក្សា និងអភិវឌ្ឍដើម្បីគាំទ្រគ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍសម្រាប់បុគ្គលិកថ្មី និងដែលមានស្រាប់ ដោយចាប់ផ្តើមពីថ្នាក់តូច រហូតដល់អ្នកដឹកនាំជាន់ខ្ពស់នៃអាជីវកម្មរបស់យើងតាមរយៈកម្មវិធីបណ្តុះបណ្តាលដ៏ទូលំទូលាយរបស់យើង។ វិធីសាស្ត្ររបស់យើងគឺដើម្បីអភិវឌ្ឍបុគ្គលិករបស់យើងរួមបញ្ចូលគ្នាជាមួយនឹងបទពិសោធន៍ការងារ ការណែនាំ ការសិក្សាតាមរយៈអ្នកដទៃ និងកម្មវិធីបណ្តុះបណ្តាលផ្លូវការទាំងខាងក្នុង និងខាងក្រៅរួមទាំងកម្មវិធីបណ្តុះបណ្តាលនៅក្រៅប្រទេសផងដែរ។ យើងបានសម្របសម្រួល និងអនុវត្តកម្មវិធីណែនាំ ការបណ្តុះបណ្តាលផ្ទៃក្នុង ការរៀនតាម អ៊ីនធឺណិត និងកម្មវិធីអភិវឌ្ឍជំនាញផ្សេងទៀតសម្រាប់បុគ្គលិក ១.១៩៣នាក់ ក្នុងឆ្នាំ ២០២១។ ការបន្តការវិនិយោគលើធនធានមនុស្សរបស់យើងគឺជាអាទិភាពសំខាន់សម្រាប់យើង។

# ផលិតផល និង សេវាកម្ម



# ១.១១ ផលិតផល និង សេវាកម្ម

ធនាគាររបស់យើងផ្តល់ជូននូវផលិតផល និងសេវាកម្មធនាគារជាច្រើនសម្រាប់បុគ្គល  និងអាជីវកម្ម។ លើសពីផលិតផលឥណទាន និងផលិតផលសន្សំ យើងក៏ផ្តល់នូវ ផលិតផលឌីជីថល សេវាផ្ទេរប្រាក់ បង់រំលស់ និងសេវាធនាគារផ្សេងទៀត ដើម្បីផ្តល់នូវសេវាកម្មល្អបំផុត និងគួរឱ្យទុកចិត្តដល់អតិថិជនរបស់យើង។

## ផលិតផលឥណទាន

## សេវាសន្សំ

## សេវាផ្ទេរប្រាក់

## សេវាភតិសន្យា

# ផលិតផលឥណទាន




## ឥណទានខ្នាតតូចបំផុត

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ទំហំឥណទាន | ៥០០ ដុល្លារ ទៅ ១០.០០០ ដុល្លារ (រូបិយប័ណ្ណសមមូល) |
| រយៈពេលកម្ចី | រហូតដល់ ៧ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទានខ្នាតតូចបំផុតគឺជាផលិតផលឥណទានដែលសមស្របសម្រាប់អតិថិជនទូទៅដែលមានចំណូលសមរម្យ រស់នៅក្នុងទីប្រជុំជន ឬជនបទ ដែលមានគោលបំណងខ្ចីប្រើប្រាស់លើមុខរបរដូចជា កសិកម្ម សេវាកម្ម សិប្បកម្ម ពាណិជ្ជកម្ម អាជីវកម្ម ជំនួញ សំណង់ ។ល។

## ឥណទានខ្នាតតូច

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ទំហំឥណទាន | ១០.០០១ដុល្លារ ទៅ ៥០.០០០ ដុល្លារ (រូបិយប័ណ្ណសមមូល) |
| រយៈពេលកម្ចី | រហូតដល់ ១០ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទានខ្នាតតូចគឺជាផលិតផលឥណទានរបស់យើងដែលសមស្របសម្រាប់អតិថិជនទូទៅដែលមានចំណូលសមរម្យរស់នៅក្នុងទីប្រជុំជន ឬជនបទ ដែលមានគោលបំណងខ្ចីប្រើប្រាស់លើមុខរបរដូចជា កសិកម្ម សេវាកម្ម សិប្បកម្ម ពាណិជ្ជកម្ម អាជីវកម្ម ជំនួញ សំណង់ ។ល។

## ឥណទានណាណូ

| រូបបិយប័ណ្ណ | ដុល្លារ |
|---|---|
| ទំហំឥណទាន | ៦លានរៀល |
| រយៈពេលកម្ចី | រហូតដល់ ២ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទាន ណាណូ គឺជាផលិតផលឥណទានមួយ ក្នុងចំណោមផលិតផលឥណទានរបស់យើងដែលសមស្របសម្រាប់អតិថិជនគ្រប់ប្រភេទដែលស្ថិតនៅក្នុងវិស័យសាធារណៈ សហគ្រាសនិងក្រុមហ៊ុនឯកជនផ្សេងទៀតនិងអតិថិជនដែលបច្ចុប្បន្នស្ថិតនៅក្រោមផលប័ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។

## ឥណទានណាណូផ្លាស

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ទំហំឥណទាន | រហូតដល់ ៥.០០០ ដុល្លារ |
| រយៈពេលកម្ចី | ២ ឆ្នាំ (បន្តរៀងរាល់ ១២ ខែម្តង) |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ណាណូផ្លាស គឺជាផលិតផលឥណទានមួយ ដែលសមស្របសម្រាប់អតិថិជនគ្រប់ប្រភេទ ដែលស្ថិតនៅក្នុងវិស័យសាធារណៈ សហគ្រាស និងក្រុមហ៊ុនឯកជនផ្សេងទៀត។ ណាណូផ្លាស អាចជាទុនបម្រុងសម្រាប់ការខ្វះខាតសាច់ប្រាក់ភ្លាមៗ។ ការផ្គត់ផ្គង់ ថ្លៃសិក្សារបស់កុមារ ការថែទាំ សង្គ្រោះបន្ទាន់ និងតម្រូវការផ្សេងទៀត ដក និងសងវិញតាមរយៈប័ណ្ណសមាជិកជាមួយភ្នាក់ងារ លី ហួរ ផេ ប្រ៉ូ នៅទូទាំងប្រទេស។

## ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម

| រូបបិយប័ណ្ណ | រៀល ដុល្លារ |
|---|---|
| ទំហំឥណទាន | រហូតដល់ ២០០.០០០ ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ១០ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម (SME Loan) ជាប្រភេទឥណទានមានទ្រព្យធានា ដែលមានទំហំធំជាង ឬស្មើ ៥០.០០០ដុល្លារ រហូតដល់ ២០០.០០០ដុល្លារអាមេរិក ឬរូបិយបណ្ណសមមូល ជាមួយលក្ខខណ្ឌងាយស្រួល សម្រាប់ម្ចាស់សហគ្រាស និងនិយោជិតសម្រាប់បង្កើតអាជីវកម្មថ្មី ឬពង្រីកអាជីវកម្មដែលមានស្រាប់ ឬទិញទ្រព្យសកម្ម ឬ សេវាសងផ្តាច់ជាមួយស្ថាប័នផ្សេង។

## ឥណទានពាណិជ្ជកម្ម

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ទំហំឥណទាន | លើសពី ២០០.០០០ ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ១០ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទានពាណិជ្ជកម្មជាប្រភេទឥណទានមានទ្រព្យធានា ដែលសមស្របសម្រាប់អតិថិជនគ្រប់ប្រភេទស្ថិតនៅក្នុងវិស័យសាធារណៈ សហគ្រាស អាជីវកម្មខ្នាតតូចនិងមធ្យម ឬក្រុមហ៊ុនឯកជនផ្សេងទៀត និងរូបវន្តបុគ្គលដែលធ្វើ ប្រតិបត្តិការណ៍អាជីវកម្មស្របច្បាប់ក្រោមបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា។ ធនាគាររបស់យើងផ្តល់នូវជម្រើសឥណទានជាច្រើនប្រភេទដូចជា ឥណទានវិបារូបវ៍ / ឥណទានវិបារូបវ៍ដែលធានាដោយប្រាក់បញ្ញើ ឥណទានអាជីវកម្មខ្នាតតូច ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម ឥណទានអាជីវកម្មមានកាលកំណត់ ឥណទានទុនបង្វិលរយៈពេលខ្លី ហិរញ្ញប្បទានគណនីទទួល លិខិតធានារបស់ធនាគារ។

## ឥណទានគេហដ្ឋាន

| រូបបិយប័ណ្ណ | ដុល្លារ |
|---|---|
| ទំហំឥណទាន | រហូតដល់៨០%នៃទ្រព្យធានា |
| រយៈពេលកម្ចី | រហូតដល់ ២០ ឆ្នាំ |
| អត្រាការប្រាក់ | អត្រាការប្រាក់ប្រកួតប្រជែង |

ឥណទានគេហដ្ឋានរបស់យើងគឺបានបង្កើតឡើងសម្រាប់ជួយអ្នកឱ្យក្លាយជាម្ចាស់ផ្ទះហើយ ពួកយើងជួយអ្នកក្នុងការអនុវត្តគោលដៅទាំងនេះ។

* លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្តន៍

# សេវាសន្សំ



## ប្រាក់បញ្ញើមានកាលកំណត់

| រូបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ៤០០.០០០ រៀល<br>១០០ ដុល្លារ<br>៤.០០០ បាត |
| រយៈពេល | រហូតដល់ ៦០ខែ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ៧.៧៥% |

គណនីប្រាក់បញ្ញើមានកាលកំណត់គឺសមរម្យសម្រាប់អតិថិជនទាំងអស់ដែលចង់ទទួលបានអត្រាការប្រាក់ខ្ពស់ជាងបើប្រៀបធៀបទៅនឹងគណនីសន្សំ/ចរន្តរបស់ពួកគាត់។ ចាប់ផ្តើមដាក់ប្រាក់ជាមួយយើងដើម្បីទទួលបានការប្រាក់ដែលអាស្រ័យលើរយៈពេលនៃការដាក់ប្រាក់ដែលអ្នកនឹងជ្រើសរើស។

## គណនីសន្សំ

| រូបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ២០.០០០ រៀល<br>៥ ដុល្លារ<br>២០០ បាត |
| រយៈពេល | តាមតម្រូវការ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ១% |

គណនីសន្សំគឺជាផលិតផលហិរញ្ញវត្ថុដែលយើងបង្កើតឡើងដើម្បីអនុញ្ញាតឱ្យអតិថិជនដាក់ប្រាក់របស់ពួកគេ និងទទួលបានអត្រាការប្រាក់ពីគណនីរបស់ពួកគេ។ អ្នកអាចបើកគណនីសន្សំនៅសាខារបស់យើងដោយដាក់ប្រាក់បញ្ញើយ៉ាងតិច ២០.០០០រៀល ឬ៥ដុល្លារ។

## គណនីចម្រើនផែនការអនាគត

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ៨០.០០០ រៀល<br>២០ ដុល្លារ<br>៨០០ បាត |
| រយៈពេល | រហូតដល់ ៣៦ខែ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ៦% |

គណនីចម្រើនផែនការអនាគតគឺជាផលិតផលហិរញ្ញវត្ថុដែលបានបង្កើតឡើងសម្រាប់អតិថិជនដែលត្រូវការអត្រាការប្រាក់បូកនឹងប្រាក់រង្វាន់បន្ថែមប្រចាំឆ្នាំ ឬដល់កាលកំណត់ពីផែនការសន្សំរបស់គាត់។ ជាមួយប្រាក់បញ្ញើអប្បបរមា ៨០.០០០ រៀល ឬ ២០ដុល្លារ សម្រាប់ការបើកគណនីនេះ។

## គណនីចម្រើនតាមបំណង

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ២.០០០.០០០ រៀល<br>៥០០ ដុល្លារ<br>២០.០០០ បាត |
| រយៈពេល | តាមតម្រូវការ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ៣.៥០% |

គណនីចម្រើនតាមបំណងគឺជាផលិតផលហិរញ្ញវត្ថុដែលបានបង្កើតឡើងសម្រាប់អតិថិជនបុគ្គល និងនីតិបុគ្គល ដែលទាមទារការដាក់ប្រាក់ និងដកប្រាក់គ្រប់ពេលពីគណនីរបស់ពួកគេ។ ជាមួយនឹងការដាក់ប្រាក់អប្បបរមាចំនួន ២.០០០.០០០ រៀល ឬ ៥០០ ដុល្លារ សម្រាប់ការបើកគណនីនេះ។

## គណនីព្រីមៀរ៍

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ៨០.០០០.០០០ រៀល<br>២០.០០០ ដុល្លារ<br>៨០០.០០០ បាត |
| រយៈពេល | តាមតម្រូវការ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ១% |

គណនីព្រីមៀរ៍គឺជាសេវាកម្មហិរញ្ញវត្ថុដែលសមរម្យសម្រាប់អតិថិជនជារូបវន្តបុគ្គល (ឯកកត្តជន) ដែលប្រើប្រាស់ជាមួយ មូលប្បទានបត្រ សម្រាប់ធ្វើប្រតិបត្តិការ ដាក់ ឬ ដក ឬ ផ្ទេរប្រាក់ ក្នុងអាជីវកម្ម ប្រចាំថ្ងៃ ។ អតិថិជនប្រភេទនេះ ត្រូវបានផ្តល់នូវការប្រាក់ខ្ពស់ ហើយថែមទាំងមានការផ្តល់នូវសេវាកម្ម ដ៏ល្អលើសគេ និងលឿនរហ័សទាន់ចិត្តដល់អតិថិជន។

## គណនីចរន្ត

| រូបបិយប័ណ្ណ | រៀល ដុល្លារ បាត |
|---|---|
| ប្រាក់បញ្ញើអប្បបរមា | ៤០០.០០០ រៀល<br>១០០ ដុល្លារ<br>៤.០០០ បាត |
| រយៈពេល | តាមតម្រូវការ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | អាចចរចារបាន |

គណនីចរន្ត គឺជាផលិតផលហិរញ្ញវត្ថុ ដែលសមរម្យសម្រាប់ អតិថិជនដែលជាបុគ្គល នីតិបុគ្គល និងស្ថាប័នហិរញ្ញវត្ថុដោយប្រើមូលប្បទានប័ត្រដើម្បីធ្វើប្រតិបត្តិការ (ដក ប្រាក់បញ្ញើ ឬផ្ទេរប្រាក់)។

* លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្តន៍

# សេវាផ្ទេរប្រាក់



## មូលប្បទានប័ត្រ

អ្នកអាចប្រើប្រាស់មូលប្បទានប័ត្រ/ មូលប្បទានប័ត្រធនាគារិក/ មូលប្បទានប័ត្របញ្ជាក់/ មូលប្បទានប័ត្រធនាគារដៃគូរ ជាមួយកម្រៃសេវាទាប និងអាចធ្វើការទូទាត់ជាមួយធនាគារក្នុងស្រុកដទៃទៀត។

## សេវាផ្ទេរប្រាក់ក្នុងស្រុក

អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាផ្ទេរប្រាក់ក្នុងស្រុក គឺមានភាពងាយស្រួល ប្រសិទ្ធភាពខ្ពស់ ភាពជឿជាក់ និងឆាប់រហ័ស។ ការផ្តួចផ្តើមរបស់យើង ក្នុងការសហការជាមួយធនាគារទាំងអស់ក្នុងប្រទេសកម្ពុជា ផ្តល់ឱ្យអតិថិជននូវការផ្ទេរប្រាក់ភ្លាមៗ ពីគណនីធនាគារ អេស ប៊ី អាយ លី ហួរ ទៅកាន់ធនាគារផ្សេងទៀតនៅទូទាំងប្រទេស។

## សេវាផ្ទេរប្រាក់តាមប្រព័ន្ធស្វីស

សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមរយៈប្រព័ន្ធស្វីស គឺជាសេវាផ្ទេរប្រាក់ដែលអាចជឿទុកចិត្តបាន។ អ្នកអាចទទួលបានបទពិសោធន៍ពីការផ្ទេរប្រាក់ប្រកបដោយសុវត្ថិភាព ភាពងាយស្រួល ឆាប់រហ័ស និងថ្លៃសេវាទាប។ សេវាកម្មនេះអាចធ្វើបាននៅគ្រប់សាខារបស់យើងទូទាំងប្រទេស។ ជាមួយការផ្ទេរប្រាក់តាមប្រព័ន្ធស្វីសទឹកប្រាក់របស់អ្នកនឹងត្រូវបានផ្ទេរដោយផ្ទាល់ទៅគណនីធនាគាររបស់អ្នកទទួលផលយ៉ាងឆាប់រហ័ស និងសុវត្ថិភាព។

**ធនាគារដៃគូ**

ការផ្ទេរប្រាក់ទៅ/មក ជាមួយរូបិយប័ណ្ណ ថៃបាត/វៀតណាមដុង/ដុល្លារអាមេរិក នឹងធ្វើតាមរយៈធនាគារដៃគូររបស់យើង ដែលអាចជួយសម្រួលដល់ការទូទាត់ទៅ និងមក ពីគណនី ធនាគារ អេស ប៊ី អាយ លី ហ្វួរ៖

| ប្រភេទរូបិយប័ណ្ណ | ធនាគារដៃគូ | ស្វីសកូដ |
|---|---|---|
| បាត/ដុល្លារ | Kasikorn Bank Public Company Limited | KASITHBK |
| ដុង/ដុល្លារ | VIETCOM BANK VIETNAM | BFTVVNVX |

## ការផ្ទេរប្រាក់ក្រៅប្រទេសតាមប្រព័ន្ធរីបផល (RIPPLE)

សេវាផ្ទេរប្រាក់អន្តរជាតិរីបផល អ្នកអាចទទួលបានបទពិសោធន៍នៃការផ្ញើប្រាក់ប្រកបដោយសុវត្ថិភាព ងាយស្រួល និងរហ័សក្នុងថ្លៃសេវាទាប។ ទឹកប្រាក់របស់អ្នកនឹងត្រូវបានផ្ទេរដោយផ្ទាល់ទៅគណនីធនាគាររបស់អ្នកទទួលផលក្នុងរយៈពេលតិចជាងមួយម៉ោង។

**ធនាគារដៃគូ**

ការផ្ទេរប្រាក់ទៅ ប្រទេសវៀតណាម ជាមួយរូបិយប័ណ្ណ វៀតណាមដុង/ដុល្លារអាមេរិក នឹងធ្វើតាមរយៈធនាគារដៃគូររបស់យើង ដែលអាចជួយសម្រួលដល់ការទូទាត់ទៅ និងមក ពីគណនី ធនាគារ អេស ប៊ី អាយ លី ហ្វួរ៖

| ប្រភេទរូបិយប័ណ្ណ | ធនាគារដៃគូ | ស្វីសកូដ |
|---|---|---|
| ដុង/ដុល្លារ | Tienphong Commercial Joint Stock Bank Vietnam (TPBank) | TPBVVNVX |

# សេវាភតិសន្យា




## សេវាភតិសន្យាម៉ូតូ

សេវាភតិសន្យាម៉ូតូគឺជាសេវាកម្មហិរញ្ញវត្ថុដែលអតិថិជនចង់ទិញម៉ូតូដោយមិនមានការទូទាត់ពេញលេញ អតិថិជនបង់រំលស់ប្រាក់មួយចំនួន (ការកក់ប្រាក់ជាមុន) ឬគ្មានការបង់ប្រាក់ជាមុន និងតាមវិធីបង់រំលស់ប្រាក់ប្រចាំខែ ឬតាមវិធីផ្សេងទៀតជាមួយលក្ខខណ្ឌជាក់លាក់នៃកិច្ចព្រមព្រៀង។ អតិថិជននឹងមានកម្មសិទ្ធិជាម្ចាស់ម៉ូតូ នៅពេលដែលការទូទាត់ត្រូវបានធ្វើឡើងនៅចុងបញ្ចប់នៃរយៈពេលនៃកិច្ចព្រមព្រៀង។

| រូបបិយប័ណ្ណ | ទំហំភតិសន្យា | រយៈពេល | អត្រាការប្រាក់ |
|---|---|---|---|
| ដុល្លារ | រហូតដល់ ១០០% នៃតម្លៃទ្រព្យ | រហូតដល់ ៦០ខែ | អត្រាការប្រាក់ប្រកួតប្រជែង |

## សេវាភតិសន្យាគ្រឿងចក្រធុនធ្ងន់

មិនមានតម្រូវការទ្រព្យបញ្ចាំ ដើម្បីទទួលបានគ្រឿងចក្រធុនធ្ងន់ ដើម្បីគាំទ្រដល់ការពង្រីក ឬកំណើននៃប្រតិបត្តិការអាជីវកម្ម ជាមួយនឹងការដំឡើងប្រចាំខែទាប និងការទូទាត់ចុះទាបបំផុត។

| រូបបិយប័ណ្ណ | ទំហំភតិសន្យា | រយៈពេល | អត្រាការប្រាក់ |
|---|---|---|---|
| ដុល្លារ | រហូតដល់ ៨៥% នៃតម្លៃទ្រព្យ | រហូតដល់ ៤៨ខែ | អត្រាការប្រាក់ប្រកួតប្រជែង |

* លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្តន៍

# ផ្លាស់ប្តូរ
# ប្តេជ្ញា
# ដើម្បីអនាគត

# ធនាគារឌីជីថល



**កម្មវិធីធនាគារចល័ត**

**អេធីអឹម**

**បញ្ជូរ** QR

**ផ្ទាំងបង្ហាញរូបភាពអតិថិជនលំដាប់ខ្ពស់**
(VIP DASHBOARD)

**គម្រោងឌីជីថលផ្សេងៗទៀត**
**នាពេលខាងមុខ**

# កម្មវិធីធនាគារចល័ត



## ● កម្មវិធីធនាគារចល័ត

កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ គឺជាកម្មវិធីសម្រាប់អតិថិជនដែលចង់ចូលប្រើគណនីរបស់ពួកគាត់គ្រប់ពេល និងជាកម្មវិធីធនាគារចល័ត ដែលបម្រើប្រជាជនកម្ពុជាទាំងអស់ និងជាដៃគូធនាគារចល័តដ៏គួរឱ្យទុកចិត្តបានរបស់អ្នក ហើយរចនាឡើងដើម្បីបំពេញតម្រូវការអ្នក និងជួយអ្នកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ អ្នកអាចពិនិត្យមើលសមតុល្យបានភ្លាមៗ បង់ថ្លៃវិក្កយបត្របានយ៉ាងរហ័ស បើកគណនីយ៉ាងងាយស្រួល និងទទួលបានមុខងារល្អៗជាច្រើនទៀតដែលមានព័ត៌មានលម្អិតដូចខាងក្រោម។ ទាញយក កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ ថ្ងៃនេះ!

### ហេតុអ្វីត្រូវប្រើធនាគារចល័ត អេស ប៊ី អាយ លី ហួរ?

- សមត្ថភាពកាន់តែល្អឥតខ្ចោះទាំងនៅលើឧបករណ៍ Android និង iOS។
- ទទួលបានការ ការពារ និងរីករាយជាមួយសេវាធនាគារដោយគ្មានហានិភ័យ។
- ចូលប្រើប្រាស់ទឹកប្រាក់បានគ្រប់ពេលវេលា។
- ទាញយកដោយឥតគិតថ្លៃ ហើយប្រែក្លាយទូរសព្ទដៃទៅជាធនាគារ។

## មុខងារថ្មីៗ៖

- ពិនិត្យសមតុល្យ៖ មើលគណនីរបស់អ្នកទាំងអស់នៅកន្លែងតែមួយដោយគ្រាន់តែចុចមួយដង។
- ផ្ញើប្រាក់ទៅនរណាម្នាក់៖ ផ្ទេរប្រាក់ទៅគណនីអេស ប៊ី អាយ លី ហួរ ណាមួយក្នុងរយៈពេលប៉ុន្មានវិនាទី។
- បញ្ចូលទឹកប្រាក់ទូរសព្ទចល័តណាមួយ៖ រីករាយជាមួយលេខ PIN ហើយបញ្ចូលលេខ PIN ទៅលេខរបស់អ្នក។
- ទទួលបានការជូនដំណឹងអំពីប្រតិបត្តិការភ្លាមៗ អ្នកនឹងត្រូវបានជូនដំណឹងអំពីហិរញ្ញវត្ថុរបស់អ្នកគ្រប់ពេលវេលា។
- បង្កើតគំរូភ្លាមៗ៖ សន្សំពេលវេលារបស់អ្នកដោយបន្ថែមគំរូប្រតិបត្តិការសម្រាប់មិត្តភក្តិរបស់អ្នក ឬការទូទាត់វិក្កយបត្រ។
- ការពារទឹកប្រាក់របស់អ្នក៖ បើកដំណើរការមុខងារស្នាមម្រាមដៃ ឬ មុខងារសម្គាល់មុខការពារបន្ថែមចំពោះគណនីរបស់អ្នក។
- បើកគណនីបញ្ញើ បើកគណនីប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើបូក គណនីសន្សំ។
- អេស ប៊ី អាយ លី ហួរ ផេរ ៖ ស្កេន និងបង់ប្រាក់ជាមួយពាណិជ្ជកររបស់ អេស ប៊ី អាយ លី ហួរ ។
- គណនីរហ័ស៖ បើកគណនី អេស ប៊ី អាយ លី ហួរ ដំបូងរបស់អ្នកដោយផ្ទាល់តាមរយៈទូរសព្ទរបស់យើងក្នុងរយៈពេលពីរទៅបីនាទីដោយមិនមានឯកសារ ឬមិនបាច់ត្រូវទៅកាន់សាខា។
- ស្នើសុំប្រាក់កម្ចី៖ គ្រាន់តែបំពេញសំណើតាមកម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ។

## អត្ថប្រយោជន៍៖

ងាយស្រួល រហ័សទាន់ចិត្ត
និងមានសុវត្ថិភាពខ្ពស់

កាត់បន្ថយការចំណាយ
និងសន្សំពេលវេលា

អាចពិនិត្យមើលព័ត៌មានគណនី
និងធ្វើប្រតិបត្តិការផ្ទេរប្រាក់

កាត់បន្ថយហានិភ័យទាក់ទង
នឹងការដាក់សាច់ប្រាក់តាមខ្លួន



# អេធីអឹម

## អេធីអឹម

ម៉ាស៊ីនអេធីអឹម របស់យើងគឺជាម៉ាស៊ីនច្រកចេញចូលតែមួយ ដែលអនុញ្ញាតឱ្យអ្នកធ្វើប្រតិបត្តិការហិរញ្ញវត្ថុច្រើនក្នុងរយៈពេលប៉ុន្មាននាទីប៉ុណ្ណោះ និងជាបណ្តាញអេធីអឹមដ៏ធំទូលាយដែលជួយឱ្យអ្នកអាចចូលទៅកាន់គណនីរបស់អ្នកបានភ្លាមៗ គ្រប់ពេលវេលា។ ម៉ាស៊ីនអេធីអឹមរបស់យើង អនុញ្ញាតឱ្យអ្នកធ្វើប្រតិបត្តិហិរញ្ញវត្ថុមូលដ្ឋានដែលជាសាច់ប្រាក់ និងប័ណ្ណក្នុង ២៤/៧ ដោយមិនត្រូវការទៅកាន់បញ្ជររបស់ធនាគារឡើយ៖

- ដកប្រាក់ បានជាប្រាក់ ដុល្លារ និង ប្រាក់រៀល
- ដាក់ប្រាក់ បានជាប្រាក់ ដុល្លារ និង ប្រាក់រៀល
- ពិនិត្យសមតុល្យ សាច់ប្រាក់
- បោះពុម្ពរបាយការណ៍ សង្ខេប
- ប្តូរលេខសង្ងាត់ របស់ប័ណ្ណ

## ទីតាំង / សេវាធនាគារដោយខ្លួនឯង ជាមួយ ម៉ាស៊ីន អេធីអឹម ២៤/៧៖

- សាខា ទួលគោក
- សាខា ៧ មករា
- សាខា ជ្រោយចង្វារ
- សាខា ចំការមន
- សាខា ច្បារអំពៅ (១)
- សាខា ខេត្តកោះកុង
- សាខា ខេត្តកំពង់ស្ពឺ
- សាខា ខេត្តស្ទឹងត្រែង

ទីតាំងម៉ាស៊ីន អេធីអឹម កាន់តែច្រើនឡើងៗ នឹងមកដល់ក្នុងពេលឆាប់ៗនេះ!!

# បញ្ជរ QR




## បញ្ជរ QR

ឥឡូវនេះ អ្នកអាចមកកាន់សាខារបស់យើង ដើម្បីធ្វើការដាក់ប្រាក់ ឬដកប្រាក់យ៉ាងរលូនដោយមិនចាំបាច់មានឯកសារ ហត្ថលេខាណាមួយដែលត្រូវការ ដោយគ្រាន់តែចូលទៅកាន់កម្មវិធី ធនាគារចល័ត អេស ប៊ី អាយ លី ហួរ របស់យើង ហើយស្កេន QR នៅលើបញ្ជរ ដើម្បីចាប់ផ្ដើមប្រតិបត្តិការ។ បុគ្គលិករបស់យើងនឹងរៀបចំ ហើយបម្រើតាមតម្រូវការរបស់អ្នក។

- ប្រតិបត្តិការរហ័ស និងមានសុវត្ថិភាពតាមរយៈ QR របស់យើងនៅបញ្ជរ
- ការដាក់ប្រាក់ និងការដកប្រាក់ចូលទៅក្នុង ឬពីគណនីរបស់អ្នកដោយការស្កេន និងធ្វើប្រតិបត្តិការដោយជំហានងាយៗ។

# ផ្ទាំងបង្ហាញរូបភាពអតិថិជនលំដាប់ខ្ពស់
# (VIP DASHBOARD)

## ផ្ទាំងបង្ហាញរូបភាពអតិថិជនលំដាប់ខ្ពស់ (VIP DASHBOARD)

នៅពេលណាដែល អតិថិជនលំដាប់ខ្ពស់ មកកាន់ ធនាគារព្រីមៀរ៍ របស់យើង ផ្ទាំងបង្ហាញរូបភាពអតិថិជនលំដាប់ខ្ពស់របស់យើងនឹងដំណើរការទទួលស្គាល់ថាអតិថិជនជានរណា ហើយដាក់បង្ហាញរូបភាពអតិថិជនលំដាប់ខ្ពស់ លើអេក្រង់ផ្ទាំងគ្រប់គ្រងរបស់យើងនៅក្នុងបរិវេណធនាគារព្រីមៀរ៍ខណៈពេលដែលជូនដំណឹងដល់ប្រធានផ្នែកទំនាក់ទំនងឬទីប្រឹក្សាផ្នែកលក់ដើម្បីបម្រើអតិថិជនលំដាប់ខ្ពស់ ជាមួយការរៀបចំជូននូវអាហារសម្រន់ជាពិសេសដោយឥតគិតថ្លៃ ខណៈពេលដែលកំពុងរៀបចំប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក និងបានត្រៀមខ្លួនដើម្បីផ្តល់ព័ត៌មានផ្នែកហិរញ្ញវត្ថុដើម្បីសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរបស់អ្នក។

# គម្រោងឌីជីថលផ្សេងៗទៀត
# នាពេលខាងមុខ

## គម្រោងឌីជីថលផ្សេងៗទៀតនាពេលខាងមុខ

- ត្រួតពិនិត្យទឹកប្រាក់ ផ្ទេរប្រាក់ ជាមួយនឹងក្តារចុចឌីជីថលថ្មីរបស់យើងដែលអតិថិជនអាចធ្វើប្រតិបត្តិការដោយមិនចាំបាច់ចាកចេញពីកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម និងធ្វើប្រតិបត្តិការធនាគារផ្ទាល់ពីទីនោះ។
- ការអនុម័តភ្លាមៗនៃផលិតផលកម្ចីផ្ទាល់ខ្លួនដែលមិនមានវត្ថុបញ្ចាំជាមួយបច្ចេកវិទ្យាសិក្សាម៉ាស៊ីនកម្រិតខ្ពស់របស់យើងលើការសម្រេចចិត្តឥណទាន។
- ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន វីសា នឹងត្រូវបានណែនាំ ដើម្បីបម្រើអតិថិជនឱ្យកាន់តែល្អប្រសើរ ដោយផ្តល់នូវភាពងាយស្រួលនៃការចូលទៅកាន់បណ្តាញ វីសា ទូទាំងពិភពលោក។
- គ្រប់គ្រងប័ណ្ណឥណពន្ធ ប័ណ្ណឥណទាន និងប័ណ្ណនិម្មិត យ៉ាងងាយស្រួលដោយមិនចាំបាច់ដាក់សាច់ប្រាក់ ឬមូលប្បទានប័ត្រតាមខ្លួនឡើយ។
- ផ្ញើ/ទទួលប្រាក់ភ្លាមៗពីធនាគារសមាជិកណាមួយនៃបណ្តាញបាគង។
- ដាក់សាច់ប្រាក់ចូល/ដកប្រាក់តាមធនាគារសមាជិកបាគងទាំងអស់។

# របាយការណ៍ហិរញ្ញវត្ថុ



# ០២. របាយការណ៍ហិរញ្ញវត្ថុ


២.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ____ ៥៥

២.២ របាយការណ៍របស់សវនករឯករាជ្យ ____ ៥៩

២.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ____ ៦១

២.៤ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ ____ ៦២

២.៥ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ____ ៦៣

២.៦ របាយការណ៍លំហូរទឹកប្រាក់ ____ ៦៥

# ២.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស ប៊ី អាយ លីហ្វរ ម.ក ហៅកាត់ថា "ធនាគារ" ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១។

## សកម្មភាពចម្បង

កម្មវត្ថុរបស់ធនាគារ គឺធ្វើការផ្តល់ជូននូវអាជីវកម្មធនាគារពាណិជ្ជទាំងអស់ដល់រូបវន្តបុគ្គល សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុន និងសាជីវកម្មទូទៅ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងៗទៀត ដូចដែលបានធ្វើឡើងដោយរាល់ធនាគារពាណិជ្ជអន្តរជាតិទាំងអស់។ គោលបំណងរបស់ធនាគារ គឺដើម្បីជួយដល់ប្រទេសកម្ពុជា អាជីវកម្ម និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងការរីកលូតលាស់របស់អាជីវកម្ម ដោយធ្វើការផ្តល់នូវសេវាកម្មធនាគារដែលមានជំនាញវិជ្ជាជីវៈបច្ចេកវិទ្យាជឿនលឿន ជាមួយនឹងហិរញ្ញប្បទានដែលមានលក្ខខណ្ឌសមរម្យ។

ធនាគារមានសកម្មភាពអាជីវកម្មចម្បងៗដូចខាងក្រោម ៖

ក.ប្រតិបត្តិការនៃសកម្មភាពធនាគារតាមរយៈការផ្តល់សេវាកម្មធនាគារ និង

ខ.សកម្មភាពអាជីវកម្មផ្សេងទៀតដែលត្រូវបានចាត់ទុកថាសមស្របចំពោះធនាគារ និងដែលអនុលោមទៅតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០២១ ដូចខាងក្រោម៖

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញ/(ខាត)សុទ្ធមុនដកពន្ធលើប្រាក់ចំណេញ | ៧.៩៤៨.៨៦១ | ៣២.៣៣៥.៩៦៦ | (៩៩៥.៥៤៤) | (៤.០៥៨.៨៣២) |
| (ចំណាយ)/អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណេញ | (១.៨២៧.៤៧១) | (៧.៤៣៤.៩៥២) | ២១៣.១៩៩ | ៨៦៩.២១២ |
| ប្រាក់ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ | (៧៨២.៣៤៥) | ៣.១៨៩.៦២០ |

## ភាគលាភ

សម្រាប់ការិយបរិច្ឆេទសវនកម្មនេះពុំមានការប្រកាស ឬការបែងចែកភាគលាភនោះទេ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឱ្យមានការបែងចែកភាគលាភនោះដែរ

## ដើមទុន

ពុំមានការប្រែប្រួលដើមទុនរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទសវនកម្មនេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុងនិងសំវិធានធនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទាន និងបុរេប្រទាន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបចោលនៃឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើងហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោលហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់លើការបាត់បង់ឥណទាន និងបុរេប្រទាន។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទាន និងបុរេប្រទានអាក្រក់ដែលបានលុបចោល ឬចំនួននៃការធ្វើសំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យ សកម្មដែល បានកត់ត្រានៅក្នុង បញ្ជីគណនេយ្យរបស់ធនាគារដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានបន្ថយឱ្យនៅស្មើនឹងតម្លៃដែលអាចរំពឹងថានឹងអាចប្រមូលបានជាក់ស្តែង។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយ របស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយឬ

(ខ)បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលធនាគារត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុង ការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលសភាពការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ពុំបានពិនិត្យឃើញ សភាពការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ គណៈគ្រប់គ្រង លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការពីព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេលើកលែងតែ៖

## វីរុសកូរ៉ូណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍ទុក នៅក្នុងការិយបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃវីរុសណូវែលកូរ៉ូណា (កូវីដ-១៩) បានរាតត្បាតទូទាំងសកលលោក ដែលព្រឹត្តិការណ៍បានធ្វើឱ្យមានការរាំងស្ទះដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងសូចនាករសំខាន់ផ្សេងៗ ត្រូវបានយកមកពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការខាតបង់ឥណទានរំពឹងទុកដោយក្នុងនោះការគណនាលើការខាតបង់ឥណទានរំពឹងទុកនៅក្នុងស្ថានភាពបច្ចុប្បន្នអាចមានភាពមិនប្រាកដប្រជាជាសារវន្ត។ អ្នកគ្រប់គ្រងបានធ្វើការប៉ាន់ប្រមាណលើផលប៉ះពាល់ដែលអាចកើតឡើងចំពោះធនាគារពីជំងឺកូវីដ-១៩ ប៉ុន្តែការប៉ាន់ប្រមាណនេះអាចនឹងមានការផ្លាស់ប្តូរជាសារវន្តពេលមានព្រឹត្តិការណ៍ថ្មីកើតឡើង។

នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការព្រឹត្តិការណ៍ឬធាតុណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលទំនងជាអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| អ្នកឧកញ៉ា លី ហួរ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Makoto Miyazaki | អភិបាល |
| លោក Eiichiro So | អភិបាល |
| លោក Shuzo Shikata | អភិបាល |
| ឧកញ៉ា លី សុភាព | អភិបាល (តែងតាំងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១) |
| លោក ខែក រ៉ាវី | អភិបាលឯករាជ្យ |
| លោក កែណែម វីដាណូ | អភិបាលឯករាជ្យ |
| លោក ហូរ វរៈបុត្ត | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១) |
| ឧកញ៉ា លី សុភ័ក្ត | អភិបាល (លាលែងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១) |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

អភិបាលដែលបានកាន់តំណែងនៅចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុនិងជាភាគទុនិករបស់ធនាគារមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| អ្នកឧកញ៉ា លី ហួរ | ២២.៥០០.០០០ | ២២.៥០០.០០០ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជា ភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃទៀត។

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានអភិបាលរបស់ធនាគារណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបដែលបានទទួល ឬដល់កាលកំណត់ដែលនឹងត្រូវទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយក្រុមហ៊ុនណាមួយ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬក៏ធ្វើឡើងជាមួយធនាគារណាមួយដែលអភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "ស.រ.ទ.ហ.អ.ក" ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យនិងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការនិងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តតាមនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី៦១ ដល់ទី៦៦ ថាជាសារវន្តបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
"ស.រ. ទ.ហ.អ.ក" ។

ចុះហត្ថលេខាដោយយោងលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖




អ្នកឧកញ៉ា លី ហួរ
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

# ២.២ របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក "ធនាគារ" ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី៦១ ដល់ទី៦៦ ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ"។ ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្តបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "ស.រ. ទ.ហ.អ.ក."។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដាទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដាទាំងនោះ។យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី៥៥ ដល់ទី៥៨ និងរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ដែលរំពឹងថានឹងរួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយហើយយើងខ្ញុំក៏មិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនេះ មានអសង្គតិភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬក៏ព័ត៌មានផ្សេងៗនេះបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកទៅលើការអានព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មអាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាហើយ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាក

ដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។ អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុ ទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការ សម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំឬកំហុសឆ្គងនិងទទួលខុសត្រូវលើការរៀបចំនិងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយ សារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិត គ្នា ការលួចបន្លំការលុបចោលដោយចេតនាការបកស្រាយមិនពិតឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលធនាគារបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្តយើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋាន របស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- ធ្វើការវាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូលដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការនិងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនម្ម និងការរកឃើញ បញ្ហាជាសារវន្ត ដែលរួមបញ្ចូលទាំងចំនុចខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ហ្គេក ឆាវ

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

# ២.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១

| | ៣១ ខែធ្នូ ឆ្នាំ២០២១ | | ៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦៣.០៧១.៥២១ | ២៥៦.៩៥៣.៣៧៧ | ១៤.៩៨៣.២៥៧ | ៦០.៦០៧.២៧៤ |
| ប្រាក់តម្កល់តាមច្បាប់ | ៣៣.០៩១.១៥៧ | ១៣៤.៨១៣.៣៧៤ | ១២.៧៧៤.៣៦៤ | ៥១.៦៧២.៣០២ |
| ឥណទាន និងបុរេប្រទាន | ៤៩៩.២៩៤.៩១៨ | ២.០៣៤.១២៧.៤៩៦ | ១៩៥.២៩៣.៣១២ | ៧៨៩.៩៦១.៤៤៧ |
| ទ្រព្យសកម្មផ្សេងៗ | ៣.១០២.៨១៤ | ១២.៦៤០.៨៦៤ | ៩៦២.៧៤៣ | ៣.៨៩៤.២៩៦ |
| ទ្រព្យសកម្មអរូបី | ៣.១៦៦.៥៥២ | ១២.៩០០.៥៣៣ | ២.៥៣៦.៧១២ | ១០.២៦១.០០០ |
| ទ្រព្យ និងបរិក្ខារ | ៩.២៤៨.៧៧៦ | ៣៧.៦៧៩.៥១៣ | ៥.៦០៣.៩២៩ | ២២.៦៦៧.៨៩៣ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១១.៥៥១.៣១៧ | ៤៧.០៦០.០៦៥ | ១១.១៦៦.០១០ | ៤៥.១៦៦.៥១០ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ២១០.៧០៧ | ៨៥៨.៤២០ | ៤៦៣.៩៤៨ | ១.៨៧៦.៦៧០ |
| **ទ្រព្យសកម្មសរុប** | ៦២២.៧៣៧.៧៦២ | ២.៥៣៧.០៣៣.៦៤២ | ២៤៣.៧៨៤.២៧៥ | ៩៨៦.១០៧.៣៩២ |
| **បំណុល និងមូលធនបំណុលបំណុល** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ២៦៨.៤៥៧.១២៤ | ១.០៩៣.៦៩៤.៣២៣ | ៥៣.៤៨១.៤៩០ | ២១៦.៣៣២.៦២៧ |
| ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុនានា | ១៧៥.៩៥៦.៨៤៩ | ៧១៦.៨៤៨.២០៣ | ៦៦.០៥២.៦៩៤ | ២៦៧.១៨៣.១៤៧ |
| មូលបត្របំណុល | ១៥.១១៧.៣៧២ | ៦១.៥៨៨.១៧៤ | - | - |
| ប្រាក់កម្ចី | ៣១.៥០១.៧២៤ | ១២៨.៣៣៨.០២៤ | ៣៦.៩៥៧.០១៧ | ១៤៩.៤៩១.១៣៤ |
| អនុបំណុល | ៣៣.១៦៥.៥៥២ | ១៣៥.១១៦.៤៥៩ | - | - |
| បំណុលភតិសន្យា | ១១.៧២៨.៤៩៧ | ៤៧.៧៨១.៨៩៧ | ១១.០៣៦.៨៣១ | ៤៤.៦៤៣.៩៨១ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ៧០.១៩២ | ២៨៥.៩៦២ | ៩៤.០១០ | ៣៨០.២៧០ |
| បំណុលផ្សេងៗ | ៣.៨១៤.៥៦៤ | ១៥.៥៤០.៥៣៣ | ២៥២.៧២៣ | ១.០២២.២៦៥ |
| បំណុលពន្ធអប្បបរមា | - | - | ២៤.៥០៩ | ៩៩.១៣៩ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ៩១៩.៤៩៧ | ៣.៧៤៦.០៣១ | - | - |
| **បំណុលសរុប** | ៥៤០.៧៣១.៣៧១ | ២.២០២.៩៣៩.៦០៦ | ១៦៧.៨៩៩.២៧៤ | ៦៧៩.១៥២.៥៦៣ |
| **មូលធន** | | | | |
| ដើមទុន | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ |
| ទុនបម្រុងកាតព្វកិច្ច | ២០៩.៣៤៥ | ៨៤៩.៨០៤ | ១១៣.២២០ | ៤៥៨.៧៦៧ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៤.៩៧០.៦៦២ | ២០.២០៤.៧៧៤ | ៣.០៤៨.៦៩៦ | ១២.៣៨៦.២១៦ |
| ប្រាក់ចំណេញរក្សាទុក/(ប្រាក់ខាតបង្គរ) | ១.៨២៦.៣៨៤ | ៧.៣៨២.៣៦៩ | (២.២៧៦.៩១៥) | (៩.៣០៩.៨៥០) |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | - | ២.៦០៣.១៥៤ | - | ៣៦៥.៧៦១ |
| មូលធនសរុប | ៨២.០០៦.៣៩១ | ៣៣៤.០៩៤.០៣៦ | ៧៥.៨៨៥.០០១ | ៣០៦.៩៥៤.៨២៩ |
| **បំណុល និងមូលធនសរុប** | ៦២២.៧៣៧.៧៦២ | ២.៥៣៧.០៣៣,៦៤២ | ២៤៣.៧៨៤.២៧៥ | ៩៨៦.១០៧.៣៩២ |

# ២.៤ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | ៤៩.១៥០.៥១២ | ១៩៩.៩៤៤.២៨៣ | ១៨.៦០១.៦៧៥ | ៧៥.៨៣៩.០២៩ |
| ចំណាយលើការប្រាក់ | (១៧.៧៦៦.៩៦២) | (៧២.២៧៦.០០២) | (៦.៤៥០.៧១៨) | (២៦.២៩៩.៥៧៧) |
| **ចំណូលពីការប្រាក់សុទ្ធ** | ៣១.៣៨៣.៥៥០ | ១២៧.៦៦៨.២៨១ | ១២.១៥០.៩៥៧ | ៤៩.៥៣៩.៤៥២ |
| ចំណូលសុទ្ធពីប្រាក់កម្រៃ និងជើងសា | ២១៣.៥១១ | ៨៦៨.៥៦៣ | ៣៤០.៩១៤ | ១.៣៨៩.៩០៧ |
| ចំណូលផ្សេងៗ | ២៩៥.២៧០ | ១.២០១.១៩៨ | ៣១៤.៥៣៨ | ១.២៨២.៣៧១ |
| **ចំណេញពីប្រតិបត្តិការសរុប** | ៣១.៨៩២.៣៣១ | ១២៩.៧៣៨.០០២ | ១២.៨០៦.៤០៩ | ៥២.២១១.៧៣០ |
| ចំណាយលើបុគ្គលិក | (១៤.៣៩២.៩៩៣) | (៥៨.៥៥០.៦៩៥) | (៧.៣១៨.១៧៨) | (២៩.៨៣៦.២១២) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៧.៦៣៤.៥៤៣) | (៣១.០៥៧.៣២១) | (៥.៤៦៩.០១៧) | (២២.២៩៧.១៨២) |
| ចំណាយពន្ធអប្បបរមា | - | - | (១៩៣.៣៧០) | (៧៨៨.៣៦៩) |
| **ចំណាយលើប្រតិបត្តិការសរុប** | (២២.០២៧.៥៣៦) | (៨៩.៦០៨.០១៦) | (១២.៩៨០.៥៦៥) | (៥២.៩២១.៧៦៣) |
| **ចំណេញ/(ខាត)មុនដកឱនភាពនៃ តម្លៃឧបករណ៍ហិរញ្ញវត្ថុ** | ៩.៨៦៤.៧៩៥ | ៤០.១២៩.៩៨៦ | (១៧៤.១៥៦) | (៧១០.០៣៣) |
| ការខាតបង់លើឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ | (១.៩១៥.៩៣៤) | (៧.៧៩៤.០២០) | (៨២១.៣៨៨) | (៣.៣៤៨.៧៩៩) |
| **ចំណេញ/(ខាត)សុទ្ធមុនដកពន្ធលើប្រាក់ចំណេញ** | ៧.៩៤៨.៨៦១ | ៣២.៣៣៥.៩៦៦ | (៩៩៥.៥៤៤) | (៤.០៥៨.៨៣២) |
| (ចំណាយ)/អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណេញ | (១.៨២៧.៤៧១) | (៧.៤៣៤.១៥២) | ២១៣.១៩៩ | ៨៦៩.២១២ |
| **ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ** | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ | (៧៨២.៣៤៥) | (៣.១៨៩.៦២០) |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ២.២៣៧.៣៩៣ | - | (២.១២២.៥៣៧) |
| **លទ្ធផល/(ខាត)លម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | ៦.១២១.៣៩០ | ២៧.១៣៩.២០៧ | (៧៨២.៣៤៥) | (៥.៣១២.១៥៧) |

# ២.៥ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

| | ដើមទុន | | ទុនបម្រុងកាតព្វកិច្ច | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៦៨.៩០២.០៧១ | ២៧៨.៣៥៧.៣២៣ | ១១៣.២២០ | ៤៥៨.៧៦៧ |
| **ប្រតិបត្តិការជាមួយភាគទុនិករបស់ធនាគារ** | | | | |
| ការបោះផ្សាយភាគហ៊ុន | ៦.០៩៧.៩២៩ | ២៤.៦៩៦.៦១២ | - | - |
| | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ១១៣.២២០ | ៤៥៨.៧៦៧ |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ២៤) | - | - | - | - |
| **លទ្ធផលលម្អិត** | | | | |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - |
| | - | - | - | - |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ១១៣.២២០ | ៤៥៨.៧៦៧ |
| | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ១១៣.២២០ | ៤៥៨.៧៦៧ |
| **ប្រតិបត្តិការមូលធនផ្សេងៗ៖** | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅមូលនិធិបម្រុងតាមច្បាប់(កំណត់សម្គាល់ ២៣) | - | - | ៩៦.១២៥ | ៣៩១.០៣៧ |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ២៤) | - | - | - | - |
| លទ្ធផលលម្អិត | | | | |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - |
| | - | - | - | - |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ២០៩.៣៤៥ | ៨៤៩.៨០៤ |

| ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក/(ប្រាក់ខាតបង្គរ) | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|
| ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ | ១៤២.៥២៨ | ៥៥៤.២១៩ | - | ២.៤៨៨.២៩៨ | ៧០.៥៦៩.៤១៧ | ២៨៧.៥៧០.៣៧៤ |
| - | - | - | - | - | - | ៦.០៩៧.៩២៩ | ២៤.៦៩៦.៦១២ |
| ១.៤១១.៥៩៨ | ៥.៧១១.៧៦៧ | ១៤២.៥២៨ | ៥៥៤.២១៩ | - | ២.៤៨៨.២៩៨ | ៧៦.៦៦៧.៣៤៦ | ៣១២.២៦៦.៩៨៦ |
| ១.៦៣៧.០៩៨ | ៦.៦៧៤.៤៤៩ | (១.៦៣៧.០៩៨) | (៦.៦៧៤.៤៤៩) | - | - | - | - |
| - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) |
| - | - | - | - | - | (២.១២២.៥៣៧) | - | (២.១២២.៥៣៧) |
| - | - | (៧៨២.៣៤៥) | (៣.១៨៩.៦២០) | - | (២.១២២.៥៣៧) | (៧៨២.៣៤៥) | (៥.៣១២.១៥៧) |
| ៣.០៤៨.៦៩៦ | ១២.៣៨៦.២១៦ | (២.២៧៦.៩១៥) | (៩.៣០៩.៨៥០) | - | ៣៦៥.៧៦១ | ៧៥.៨៨៥.០០១ | ៣០៦.៩៥៤.៨២៩ |
| ៣.០៤៨.៦៩៦ | ១២.៣៨៦.២១៦ | (២.២៧៦.៩១៥) | (៩.៣០៩.៨៥០) | - | ៣៦៥.៧៦១ | ៧៥.៨៨៥.០០១ | ៣០៦.៩៥៤.៨២៩ |
| - | - | (៩៦.១២៥) | (៣៩១.០៣៧) | - | - | - | - |
| ១.៩២១.៩៦៦ | ៧.៨១៨.៥៥៨ | (១.៩២១.៩៦៦) | (៧.៨១៨.៥៥៨) | - | - | - | - |
| - | - | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ | - | - | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ |
| - | - | - | - | - | ២.២៣៧.៣៩៣ | - | ២.២៣៧.៣៩៣ |
| - | - | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ | - | ២.២៣៧.៣៩៣ | ៦.១២១.៣៩០ | ២៧.១៣៩.២០៧ |
| ៤.៩៧០.៦៦២ | ២០.២០៤.៧៧៤ | ១.៨២៦.៣៨៤ | ៧.៣៨២.៣៦៩ | - | ២.៦០៣.១៥៤ | ៨២.០០៦.៣៩១ | ៣៣៤.០៩៤.០៣៦ |

# ២.៦ របាយការណ៍លំហូរទឹកប្រាក់

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ | ៦.១២១.៣៩០ | ២៤.៩០១.៨១៤ | (៧៨២.៣៤៥) | (៣.១៨៩.៦២០) |
| និយ័តកម្មលើ៖ | | | | |
| ចំណាយ/(អត្ថប្រយោជន៍) ពន្ធលើប្រាក់ចំណេញ | ១.៨២៧.៤៧១ | ៧.៤៣៤.១៥២ | (២១៣.១៩៩) | (៨៦៩.២១២) |
| ចំណាយពន្ធអប្បបរមា | - | - | ១៩៣.៣៧០ | ៧៨៨.៣៦៩ |
| រំលស់ | ៣.០៦៦.៧៩៩ | ១២.៤៧៥.៧៣៨ | ១.៦៩០.៣៧៤ | ៦.៨៩១.៦៥៤ |
| ចំណេញ/(ខាត) មិនទាន់កើតឡើងជាក់ស្តែង | ៤៣៣.៦២០ | ១.៧៦៣.៩៦៦ | (៦៧.៦៤១) | (២៧៥.៧៧២) |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ៥២៤.៥៤៦ | ២.១៣៣.៨៥៣ | ៣១៥.១២១ | ១.២៨៤.៧៤៨ |
| ចំណូលសុទ្ធពីការប្រាក់ | (៣១.៣៨៣.៥៥០) | (១២៧.៦៦៨.២៨១) | (១២.១៥០.៩៥៧) | (៤៩.៥៣៩.៤៥២) |
| ការខាតបង់លើឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ | ១.៩១៥.៩៣៤ | ៧.៧៩៤.០២០ | ៨២១.៣៨៨ | ៣.៣៤៨.៧៩៩ |
| | (១៧.៤៩៣.៧៩០) | (៧១.១៦៤.៧៣៨) | (១០.១៩៣.៨៨៩) | (៤១.៥៦០.៤៨៦) |
| បម្រែបម្រួលនៃ៖ | | | | |
| ឥណទាន និងបុរេប្រទាន | (៣០៤.៤៣៥.៨៨៧) | (១.២៣៨.៤៤៥.១៨៨) | (៩៨.០៤៨.៥៦៧) | (៣៩៩.៧៤៤.០០៨) |
| ប្រាក់តម្កល់តាមច្បាប់ | (២០.៣១៦.៧៩៣) | (៨២.៦៤៨.៧១៤) | (១១.៩៧៤.៣៦៤) | (៤៨.៨១៩.៤៨២) |
| ប្រាក់បញ្ញើរបស់អតិថិជន | ២១០.២៣៥.៩០៩ | ៨៥៥.២៣៩.៦៧៨ | ៨.៨២១.០៤៤ | ៣៦.៩៥២.៥៣៣ |
| ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុនានា | ១០៩.៩០៤.១៥៥ | ៤៤៧.០៩០.១០២ | ១០៩.៩០៤.១៥៥ | ៤៤៧.០៩០.១០៣ |
| ទ្រព្យសកម្មផ្សេងៗ | (២.២៩៧.០២៤) | (៩.៣៤៤.២៩៤) | (១.៣៣១.៨១៤) | (៥.៤២៩.៨០៦) |
| បំណុលផ្សេងៗ | ៣.៥៦១.៨៤១ | ១៤.៤៨៩.៥៦៩ | (១.០០៣.៧៤៨) | (៤.០៩២.២៨១) |
| **សាច់ប្រាក់ប្រើប្រាស់ក្នុង ប្រតិបត្តិការ** | (២០.៨៤១.៥៨៩) | (៨៤.៧៨៣.៥៨៥) | (៣.៨២៧.១៨៣) | (១៥.៦០៣.៤២៧) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (៥៤៨.៣៦៤) | (២.២៣០.៧៤៥) | (៣១៥.០២៥) | (១.២៨៤.៣៥៧) |
| ចំណូលការប្រាក់បានទទួល | ៤៧.១៨៣.៩៩៩ | ១៩១.៩៤៤.៥០៨ | ១៨.០៥៨.៦៣៤ | ៧៣.៦២៥.០៥១ |
| ចំណាយការប្រាក់បានបង់ | (១២.១០០.៩៨៤) | (៤៩.២២៦.៨០៣) | (៤.៨៧១.១៨៨) | (១៩.៨៥៩.៨៣៣) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៦៧៩.២៤២) | (២.៧៦៣.១៥៦) | (៦៣៤.១៩៥) | (២.៥៨៥.៦១៣) |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពប្រតិបត្តិការ** | ១៣.០១៣.៨២០ | ៥២.៩៤០.២១៩ | ៨.៤១១.០៤៣ | ៣៤.២៩១.៨២១ |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ  និងទ្រព្យសកម្មអរូបី | (៥.៥៥២.០២៤) | (២២.៥៨៥.៦៣៣) | (៧.៤២៩.២២៥) | (៣០.២៨៨.៩៥០) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | (៥.៥៥២.០២៤) | (២២.៥៨៥.៦៣៣) | (៧.៤២៩.២២៥) | (៣០.២៨៨.៩៥០) |

# ២.៦ របាយការណ៍លំហូរទឹកប្រាក់(ត)

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ២១.៩១៥.៣៤៣ | ៨៩.១៥១.៦១៥ | ១៣.៤៦៥.៤០៧ | ៥៤.៨៩៨.៤៦៤ |
| ការទូទាត់សងប្រាក់កម្ចី | (២៧.៣៦៣.៧៨០) | (១១១.៣១៥.៨៥៧) | (៥៣.៣៧៥.៩៦០) | (២១៧.៦១៣.៧៨៩) |
| ការទូទាត់បំណុលភតិសន្យា | (២.១១៥.៩១៤) | (៨.៦០៧.៥៣៨) | (១.៣៨៣.៩៧៧) | (៥.៦៤២.៤៧៤) |
| សាច់ប្រាក់ទទួលបានពីមូលបត្របំណុល | ១៥.០០០.០០០ | ៦១.០២០.០០០ | - | - |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | ៣៣.១៥១.៦៩៣ | ១៣៤.៨៦១.០៨៧ | - | - |
| សាច់ប្រាក់ទទួលបានពីការបង្កើនដើមទុន | - | - | ៦.០៩៧.៩២៩ | ២៤.៨៦១.២៥៧ |
| សាច់ប្រាក់សុទ្ធទទួលបាន/(ប្រើប្រាស់ក្នុង)សកម្មភាពហិរញ្ញប្បទាន | ៤០.៥៨៧.៣៤២ | ១៦៥.១០៩.៣០៧ | (៣៥.១៩៦.៦០១) | (១៤៣.៤៩៦.៥៤២) |
| ការកើនឡើង/(ថយចុះ)នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៤៨.០៤៩.១៣៨ | ១៩៥.៤៦៣.៨៩៣ | (៣៤.២១៤.៧៨៣) | (១៣៩.៤៩៣.៦៧១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | ១៥.០៣២.៩៤១ | ៦០.៨០៨.២៤៦ | ៤៩.២៤៧.៧២៤ | ២០០.៦៨៤.៤៧៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៧២៤.២៥១ | - | (៣៨២.៥៥៨) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ | ៦៣.០៨២.០៧៩ | ២៥៦.៩៩៦.៣៩០ | ១៥.០៣២.៩៤១ | ៦០.៨០៨.២៤៦ |

# បណ្ដាញការិយាល័យទំនាក់ទំនង



# ០៣.បណ្តាញការិយាល័យទំនាក់ទំនង


៣.១ ការិយាល័យស្តង់ដា ៦៩

៣.២ បណ្ណាញសាខា ៧៣

# ៣.១ ការិយាល័យស្តង់ដា



## ការិយាល័យស្តង់ដា




VIP 1
VIP 2
VIP 3


Self-Service Banking
ATM 24/7
ATM / CDM


10
11
12
ripple
Welcome to SBILH


សន្សំជាមួយ
អត្រាការប្រាក់ខ្ពស់
7.75%
SBI LY HOUR Bank

# ការិយាល័យស្តង់ដា











# ៣.២ បណ្តាញសាខា



## ការិយាល័យកណ្តាល

អគារលេខ២១៩ ផ្លូវ១២៨ កែង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរសព្ទលេខ : ០២៣ ៩៨០ ៨៨៨
អ៊ីម៉ែល : info@sbilhbank.com.kh
គេហទំព័រ : www.sbilhbank.com.kh

**បណ្តាញសាខាទាំង**

**៤៥**

**ក្នុង ២៥ ខេត្ត រាជធានី**

## ការិយាល័យសាខា

| | | |
|---|---|---|
| សាខា ៧មករា ០១៥ ៨៨៥ ១១៦<br>អគារលេខ២១៩ ផ្លូវ១២៨ កែង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ | សាខា ទួលគោក ០១៥ ៨៨៥ ៦៦៧<br>អគារ៨៥-៨៦-៨៧-៨៨ មហាវិថីគីមអ៊ីលស៊ុង (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ | សាខា ជ្រោយចង្វារ ០១៦ ៨៨៨ ៧៥១<br>ផ្ទះលេខ អេហ្វ០៦ (បុរីភ្នំពេញផាក) ផ្លូវជាតិលេខ៦អា សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| សាខាចំការមន ០១៥ ៨៨៥ ១២៤<br>អគារលេខ១១៨ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | សាខា ខណ្ឌច្បារអំពៅ ០១៦ ៨៨៨ ៤០៧<br>ភូមិព្រែកធំ២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជាធានីភ្នំពេញ | សាខា ច្បារអំពៅ (២) ០១៥ ៨៨៥ ១៧២<br>ផ្ទះលេខ២៥ ផ្លូវជាតិលេខ១ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ |
| សាខា ស្រុកកណ្តាលស្ទឹង ០១៦ ៨៨៨ ២៩៧<br>ផ្លូវជាតិលេខ៣ ភូមិដើមត្រាំង ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល | សាខា ស្រុកអង្គស្នួល ០១៦ ៨៨៨ ៣៧១<br>ផ្ទះលេខ១៨អា១ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល | សាខា ក្រុងដូនកែវ ០៨៧ ២៨៨ ៨៨១<br>ភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ |
| សាខា ស្រុកបាទី ០១៦ ៩៩៩ ៧៤៩<br>អាសយដ្ឋាន ភូមិបរចាម ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ | សាខា ស្រុកត្រាំកក់ ០១៦ ៨៨៨ ១៦០<br>ផ្លូវជាតិលេខ៣ ភូមិយាយឡ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ | សាខា ស្រុកកោះអណ្តែត ០១៦ ៨៨៨ ៣៩១<br>ភូមិរមេញខាងជើង ឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ |

# ការិយាល័យសាខា

| | | |
|---|---|---|
| សាខា ស្រុកគិរីវង់ ០១៥ ៨៨៥ ៣៤៧<br>ភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ | សាខា ព្រៃកប្បាស ០១៦ ៨៨៨ ៤១០<br>ភូមិផ្សារជ្រៃ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | សាខា ស្រុកកំពង់ត្រាច ០១៦ ៨៨៨ ៤២០<br>ផ្លូវជាតិលេខ៣១ ភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត |
| សាខា ខេត្តកំពង់ស្ពឺ ០១៦ ៨៨៨ ២៣៩<br>ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រកាធំ ក្រុងច្បារមន | សាខា ស្រុកសំរោងទង ០១៦ ៨៨៨ ២២៧<br>ភូមិត្រពាំងអំពិល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | សាខាស្រុកព្រៃនប់ ០១៦ ៨៨៥ ២៣៤<br>ភូមិសំរុងកណ្តាល ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ |
| ក្រុងខេមរភូមិន្ទ ០១៦ ៨៨៨ ៤២៨<br>ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង | សាខា ស្រុកកំពង់ត្រឡាច ០៨៦ ៧៤៤ ៤៤២<br>ផ្លូវជាតិលេខ៥ ភូមិច្រករមៀត ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ស្ពឺ | សាខា ស្រុកបាកាន ០១៦ ៨៨៨ ៤១១<br>ផ្លូវជាតិលេខ៥ ភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| សាខា ខេត្តបាត់ដំបង ០១៥ ៨៨៥ ១៦៦<br>ផ្ទះលេខ៦៣៩ ផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង | សាខា ស្រុកមោងឫស្សី ០១៦ ៨៨៥ ៦៤៩<br>ផ្លូវជាតលេខ៥ ភូមិកន្សែបន្ទាយ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង | សាខា ស្រុកបវេល ០១៦ ៨៨៨ ៧០១<br>ភូមិស្ពានកណ្តាល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង |
| សាខា ស្រុករតនមណ្ឌល០១៦ ៨៨៨ ៥៣៧<br>ភូមិបាណង់ ឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង | សាខា ភ្នំព្រឹក ០១៦ ៨៨៥ ៦១៩<br>ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង | សាខា ក្រុងសេរីសោភ័ណ ០៨១ ៨៦៦ ៦៦០<br>ភូមិ៤ សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ |
| សាខា ក្រុងប៉ៃលិន ០១៦ ៨៨៨ ៥១៥<br>ភូមិអូរតាពុកលើ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន | សាខា ស្រុកអន្លង់វែង ០១៦ ៨៨៨ ៧២១<br>ភូមិអូរជញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ. | សាខា ក្រុងព្រះវិហារ ០១៥ ៨៨៥ ៦៧៧<br>ភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ |
| សាខា ខេត្តកំពង់ចាម ០១៥ ៨៨៨ ៤១៩<br>ភូមិបឹងស្នាយ សង្កាត់សំបូរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម | សាខា ស្រុកបាធាយ ០៨១ ២៥៥ ៥៥៤<br>ភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម | សាខា ស្រុកជើងព្រៃ ០១៦ ៩៩៩ ៧៤៣<br>ផ្លូវជាតិលេខ៧ ភូមិតាសែន ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម |
| សាខា ក្រុងស្ទឹងសែន ០១៦ ៨៨៨ ០៦៧<br>ភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | សាខា ស្រុកប្រាសាទបាគង ០១៥ ៨៨៥ ៣៧៣<br>ផ្ទះលេខ៦០-៦១ ផ្លូវជាតិលេខ ៦អា ភូមិគោកត្នោត ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប | សាខា ស្រុកកំពង់ត្របែក ០១៦ ៨៨៨ ៥១៩<br>ភូមិចំបក់ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង |
| សាខា ស្រុកស្វាយអន្ទរ ០៨១ ៧៩៩ ៩៩៥<br>ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | សាខា ស្រុកព្រះស្តេច ០១៦ ៨៨៨ ៤០៣<br>ភូមិព្រៃមាស ឃុំអង្គររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង | សាខា ក្រុងពារាំង ០៨១ ៦៩៩ ៩៩៣<br>ភូមិស្នាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង |
| សាខា ក្រុងបាវិត ០៨១ ៨៩៩ ៩៩៥<br>ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង | សាខាក្រុងសួង ០១៦ ៨៨៨ ៦២៣<br>ភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ | សាខា ក្រុងក្រចេះ ០១៥ ៨៨៥ ៥៦៥<br>ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ |
| សាខា ក្រុងស្ទឹងត្រែង ០១៦ ៨៨៨ ៤៧៨<br>ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង | សាខា ក្រុងសែនមនោរម្យ ០១៦ ៨៨៨ ៣៦៥<br>ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | សាខា ខេត្តរតនគិរី ០៧០ ៩២៥ ៥៥៥<br>ភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី |

ធនាគារ អេស ប៊ី អាយ លី ហួរ

SBI LY HOUR Bank

w.w.w.sbilhbank.com.kh

SBI LY HOUR Bank
ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក

sbilhbank

SBI LY HOUR Bank Plc.

info@sbilhbank.com.kh

(+៨៥៥) ២៣ ៩៨០ ៨៨៨

អាសយដ្ឋានៈ អាគារ ២១៩ ផ្លូវ ១២៨ និង១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ